

# ទំហំដែលផ្ទុកអ្នកទោសបាន ឆ្នាំ២០១១: របាយការណ៍ថ្មីៗ ស្តីពី ភាពចង្អៀតណែនរបស់អ្នកទោស នៅកម្ពុជា

របាយការណ៍ លីកាដូ
ខែកក្កដា ឆ្នាំ២០១១


សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

Cambodian League for the
Promotion and Defense of Human Rights

# ទំហំដែលផ្ទុកអ្នកទោសបាន ឆ្នាំ២០១១៖ របាយការណ៍ថ្មីៗស្តីពី ភាពចង្អៀតណែនរបស់អ្នកទោស នៅកម្ពុជា

របាយការណ៍ លីកាដូ

ខែកក្កដា ឆ្នាំ២០១១

សម្ព័ន្ធខ្មែរជំរុញនិងការពារសិទ្ធិមនុស្ស លីកាដូ
LICADHO
Cambodian League for the Promotion
and Defense of Human Rights

## សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការស្ថិតនៅជួរមុខគេក្នុងកិច្ចការពារសិទ្ធិមនុស្សនៅកម្ពុជា និងលើកស្ទួយការគោរពសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតាមរយៈ រាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័ននានា។ ការកសាងសមិទ្ធិផលរបស់ខ្លួនក្នុងអតីតកាល **លីកាដូ** បានបន្តដើរតួជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងឃ្លាំមើលរដ្ឋាភិបាល តាមរយៈកម្មវិធីសិទ្ធិមនុស្សនានាពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅតាម សាខា ទូទាំង១២ ខេត្ត-ក្រុងផ្សេងទៀត។

**អង្គការលីកាដូអនុវត្តសកម្មភាពរបស់ខ្លួនតាមរយៈកម្មវិធីធំៗពីរៈ**
**កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្សៈ**

- **ឃ្លាំមើលការរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តដោយបុគ្គលរបស់រដ្ឋលើការរំលោភសិទ្ធិស្រ្តី និងការរំលោភសិទ្ធិកុមារៈ**បុគ្គលិកធ្វើការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្តដោយបុគ្គលរបស់រដ្ឋ ចំពោះការរំលោភបំពានលើស្រ្តី និងកុមារ ហើយជនរងគ្រោះត្រូវបានផ្តល់សេវាជួយជ្រោមជ្រែងតាមរយៈ ការធ្វើអន្តរាគមន៍ ជាមួយអាជ្ញាធរមូលដ្ឋាន។
- **ការប្រឹក្សាផ្នែកច្បាប់និងកិច្ចការពារផ្នែកច្បាប់ៈ**ជនរងគ្រោះត្រូវបានផ្តល់ជូននូវការប្រឹក្សាផ្នែកច្បាប់ ហើយចំពោះករណីសំខាន់ៗទទួលបាននូវកិច្ចការពារផ្នែកច្បាប់ ដែលផ្តល់ជូនដោយក្រុមប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។
- **ការឃ្លាំមើលពន្ធនាគារៈ** អ្នកស្រាវជ្រាវពន្ធនាគារធ្វើការឃ្លាំមើលពន្ធនាគារចំនួន១៨ ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានាថាពិរុទ្ធជនទទួលបាននូវតំណាងផ្នែកច្បាប់។
- **ជំនួយផ្នែកវេជ្ជសាស្រ្តៈ** ក្រុមគ្រូពេទ្យផ្តល់សេវាវេជ្ជសាស្រ្តដល់អ្នកទោស និងមន្ត្រីពន្ធនាគារចំនួន១២កន្លែង។ បន្ថែមពីលើនេះ ក៏ជួយផ្តល់សេវាវេជ្ជសាស្រ្ត និងបញ្ជូនជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្ស ទៅកាន់មន្ទីរពេទ្យ។
- **សវាកម្មសង្គមកិច្ចៈ** ក្រុមការងារធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ ហើយផ្តល់ជំនួយជាសម្ភារៈ និងម្ហូបអាហាររយៈពេលខ្លី។

**កម្មវិធីទំនាក់ទំនង និងការទាក់ទាញមតិគាំទ្រៈ**

- **ការហ្វឹកហ្វឺនសហគមន៍ អប់រំ និងការតស៊ូមតិៈ** អ្នកហ្វឹកហ្វឺន និងអ្នកតស៊ូមតិធ្វើការអប់រំ ដល់សាធារណជន អំពីសិទ្ធិស្រ្តី និងសិទ្ធិកុមារបង្កើតបណ្តាញការពារនៅតាមមូលដ្ឋាន និងធ្វើការតស៊ូមតិដើម្បីឲ្យមានការផ្លាស់ប្តូរសង្គម និងច្បាប់។

- **ការតស៊ូមតិជាសាធារណៈ និងតាមសហគមន៍:** ករណីរំលោភសិទ្ធិមនុស្សដែលស៊ើបអង្កេតដោយលីកាដូត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យ ដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិតជារបាយការណ៍ជាប្រចាំ(ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍ សោតទស្សន៍)។

**ចំពោះព័ត៌មានបន្ថែមសូមទាក់ទង**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការលីកាដូ
អាសយដ្ឋាន: អង្គការលីកាដូ (សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស)
ផ្ទះលេខ ១៦ ផ្លូវលេខ ៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (+៨៥៥) ២៣ ៧២៧ ១០២/៣៦៤ ៩០១ ទូរសារ: (+៨៥៥) ២៣ ៧២៧ ១០២/២១៧ ៦២៦
អ៊ីម៉ែល: contact@licadho-cambodia.org
គេហទំព័រ: http://www.licadho-cambodia.org/

# មាតិកា


**សេចក្ដីផ្ដើម** ---------------------------------------------------------------------------------------------- ១

**១- ភាពចង្អៀតណែនរបស់អ្នកទោស៖ ការពិនិត្យមើល ឡើង វិញនូវអ្វី ដែលបានកើតឡើង** ------------------------------------------------------------------------------- ៣

ផលប៉ះពាល់នៃភាពចង្អៀតណែនរបស់អ្នកទោស------------------------------------------------------------------------ ៥

'យុទ្ធសាស្ត្រដែលមិនទទួលបានជោគជ័យ'---------------------------------------------------------------------------- ៧

លទ្ធភាពផ្ទុកអ្នកទោសបានតាមពន្ធនាគាររបស់ប្រទេសកម្ពុជា ----------------------------------------------------- ៨

ទិន្នន័យមិនត្រឹមត្រូវនៃលទ្ធភាពផ្ទុកអ្នកទោសបានរបស់ពន្ធនាគារ: ភាពចង្អៀតណែន ហាក់ដូចជាមានសភាពកាន់តែខ្លាំងឡើងៗជាងអ្វីដែលយើងសន្និដ្ឋាន ------------------------------------------------------------ ៩

រូបភាពតំណាងបង្ហាញពីចំនួនអ្នកទោស និងភាពចង្អៀតណែនក្នុងពន្ធនាគារ (ទិន្នន័យខែមេសា ឆ្នាំ២០១១) -------------------------------------------------------------------------------- ១១

ចំនួនអ្នកទោស: ថ្វីត្បិតឃើញថាមានការកើនឡើងយឺតមែន ក៏ប៉ុន្តែនៅតែច្រើនហួស ---------------- ១៣

អត្រាឃុំឃាំងថ្នាក់ជាតិរបស់ប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ២០០៦------------------------------------------ ១៧

**២- កត្តារួមចំណែកដល់ភាពចង្អៀតណែនរបស់អ្នកទោស** ----------------------------- ១៨

ជាប់ទោសដោយសារភាពក្រីក្រ: បន្ថែមពេលជាប់ពន្ធនាគារ បើមិនអាចបង់ប្រាក់ពិន័យ ------------- ១៩

ជម្រើសផ្សេងក្រៅពីការឃុំឃាំងក្នុងពន្ធនាគារ: មិនចំចំណុចនៃបញ្ហា ------------------------------------ ២២

*ការឃុំឃាំងដោយរូបភាពផ្សេង*------------------------------------------------------------------------------------ ២៣

*ភាពចង្អៀតណែន និងទំនាក់ទំនងជាមួយនឹងបទល្មើសគ្រឿងញៀន*-------------------------------- ២៦

*"ការផ្ទេរអ្នកទោសពីកន្លែងមួយទៅកន្លែងមួយ" មិនមែនជាដំណោះស្រាយចំពោះបញ្ហាភាពចង្អៀតណែនទេ* ----------------------------------------------------------------------------------------- ២៧

ទម្លាក់ទម្ងន់លើ: បទល្មើសតូចតាច តែមានចិរវេលាយូរ ------------------------------------------------- ២៩

**៣- អនុសាសន៍ និងការពិនិត្យឡើងវិញ** -------------------------------------------------- ៣០

# សេចក្តីផ្តើម

កាលពីខែកក្កដា ឆ្នាំ២០១០ អង្គការលីកាដូ បានរាយការណ៍ថា អ្នកទោសនៅតាមពន្ធនាគាររបស់ប្រទេសកម្ពុជា មានការកើនឡើងយ៉ាងខ្លាំងដែលមិនធ្លាប់មានពីមុនមក[១]។ ពន្ធនាគារចំនួន១៨ ដែលឃ្លាំមើលដោយអង្គការលីកាដូ មានផ្ទុកអ្នកទោសរហូតដល់ទៅ ១៧៥% នៃលទ្ធភាពដែលផ្ទុកអ្នកទោសបាន។ កំណើនអ្នកទោសនៅតាមពន្ធនាគារទាំងអស់នេះ ជាមធ្យម គឺ ១៤% ក្នុងមួយឆ្នាំ ហើយប្រព័ន្ធនេះស្ថិតនៅលើផ្លូវមួយដែលនឹងនាំទៅដល់ភាពចង្អៀតណែនខ្លាំងជាងគេបំផុត នៅលើពិភពលោក នាឆ្នាំ២០១៨។

នៅខណៈពេលនេះដែរ រាជរដ្ឋាភិបាលហាក់មិនទាន់មានចំណាត់ការអ្វីចំពោះប្រព័ន្ធយុត្តិធម៌ដែលពឹងផ្អែកទាំងស្រុង លើការឃុំឃាំងក្នុងពន្ធនាគារ ជាទម្រង់ចម្បងនៃទោសនៅឡើយ។

មិនមានការផ្លាស់ប្តូរអ្វីច្រើនទេ សំរាប់រយៈពេលមួយឆ្នាំកន្លងមក ហើយចំពោះផ្នែកខ្លះវិញ មានស្ថានភាពកាន់តែធ្ងន់ធ្ងរទៅៗ។

គិតមកត្រឹមថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១១ នៅប្រទេសកម្ពុជា មានអ្នកទោសនៅក្នុងពន្ធនាគារទាំងអស់សរុបចំនួន ១៥,០០១នាក់ (មួយម៉ឺនប្រាំពាន់មួយនាក់)។ ចំនួននេះតំណាងអោយការកើនឡើង ១២.៦% តាំងពីខែមីនា ឆ្នាំ២០១០[២] នៅពេលនោះចំនួនអ្នកទោសសរុបមាន ១៣,៣២៥នាក់ (មួយម៉ឺនបីពាន់បីរយម្ភៃប្រាំនាក់)។ សព្វថ្ងៃអត្រាឃុំឃាំងមានកំរិត ១៧៩% ហើយដែលវាជាតួលេខបែបអភិរក្ស ដោយហេតុថាមានភស្តុតាងជាច្រើនដែលបង្ហាញថាតួលេខមួយចំនួននៃលទ្ធភាពដែលផ្ទុកអ្នកទោសបាន មានលក្ខណៈបំប៉ោងហួសហេតុ។

ទន្ទឹមគ្នានេះដែរឫសគល់ដែលបណ្តាលអោយមានភាពចង្អៀតណែនរបស់អ្នកទោសមិនទាន់ត្រូវបានដោះស្រាយនៅឡើយទេ។ ការដាក់ឃុំឃាំងក្នុងពន្ធនាគារ គឺជាវិធីដែលបានកំណត់សម្រាប់អនុវត្តស្ទើរគ្រប់បទល្មើសទាំងអស់ គិតចាប់ពីករណីលួចមាន់ រហូតដល់

---

[១] សូមអានរបាយការណ៍អង្គការ លីកាដូ ចេញផ្សាយក្នុងខែកក្កដា ឆ្នាំ២០១០ មានចំណងជើងថា "គុកធំ-ចង្អៀតខ្លាំង: ភាពចង្អៀតណែនរបស់អ្នកទោសនៅកម្ពុជា និងក្តីស្រមៃនៃមណ្ឌលអប់រំកែប្រែទី៩"។

[២] អគ្គនាយកដ្ឋានពន្ធនាគារមិនផ្តល់ដំណឹងទៀងទាត់ជាសាធារណៈអំពីបច្ចុប្បន្នភាពនៃចំនួនអ្នកទោសទេ។ ចំនួនអ្នកទោស ក្នុងខែមីនា ឆ្នាំ២០១០ និងក្នុងខែមេសា ឆ្នាំ២០១១ គឺជាតួលេខដែលមានសមស្របបំផុតសម្រាប់បង្ហាញពីចំនួនកើនឡើងនៃអ្នកទោសក្នុងរយៈពេលមួយឆ្នាំ។

ករណីឃាតកម្ម។ ជនប្រព្រឹត្តិបទលហុ បានជាប់ឃុំឃាំងក្នុងពន្ធនាគាររាប់ឆ្នាំ ទំរាំតែទទួលបានការដោះលែង ដោយមានការបង្ហាញពីការគិតគូរតិចតួចបំផុតអំពីសមាមាត្រនៃទោស ឬផល ប៉ះពាល់នៃប្រព័ន្ធពន្ធនាគារ។

ចិរវេលាជាប់ឃុំឃាំងក្នុងពន្ធនាគារត្រូវបានបន្តចំពោះអ្នកទោស ដែលខកខានមិនបានបង់ប្រាក់ពិន័យ។ ការដោះលែងដោយមានលក្ខខណ្ឌ ដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៩ មិនទាន់មានការអនុវត្តបានពេញលេញនៅឡើយ ហើយការឃុំខ្លួនបណ្តោះអាសន្នរងចាំសវនាការ នៅតែត្រូវបានប្រើប្រាស់យ៉ាងច្រើន។

ការប៉ុនប៉ងតែមួយគត់របស់រាជរដ្ឋាភិបាល ដើម្បីដោះស្រាយភាពចង្អៀតណែនរបស់អ្នកទោស អាចត្រូវបានបង្ហាញពីចរិកលក្ខណៈនៃការដោះស្រាយមិនចំចំណុចនៃបញ្ហា។ ដូចជា ក្នុងខែមេសា ឆ្នាំ២០១១ អាជ្ញាធរក្នុងខេត្តបន្ទាយមានជ័យ បានបញ្ជូនអ្នកទោសដែលជាប់ចោទពីបទប្រើប្រាស់គ្រឿងញៀនចំនួន ៣៨នាក់ ចេញពីពន្ធនាគារទៅកាន់មជ្ឈមណ្ឌលព្យាបាលសារធាតុញៀន ដែលគ្រប់គ្រងដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក.ស.អ.យ) ក៏ដូចគ្នានឹងពន្ធនាគារមួយទៀតដែរ។ របាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch) បានពិព័ណ៌នាពីមជ្ឈមណ្ឌលដទៃទៀត ដែលគ្រប់គ្រងដោយក្រសួងសង្គមកិច្ចថាជាទីកន្លែងសម្រាប់ធ្វើទារុណកម្ម ប្រព្រឹត្តិអំពើហិង្សាលើរាងកាយ និងផ្លូវភេទ និងប្រព្រឹត្តិបែបមិនប្រក្រតីផ្សេងទៀត។[៣]

ទាំងអស់នេះ បង្ហាញអោយមើលឃើញអំពីភាពចង្អៀតណែនខ្លាំងឡើងៗដដែលៗរបស់ពន្ធនាគារប្រទេសកម្ពុជា។ យ៉ាងតិចណាស់មានពន្ធនាគារចំនួន១២ ដែលមានចំនួនអ្នកទោសជិតពីរដង ឬពីរដងនៃលទ្ធភាពផ្ទុកអ្នកទោសបាន ហើយពន្ធនាគារខ្លះទៀតផ្តល់កន្លែងរស់នៅក្នុងបន្ទប់មានទំហំតិចជាងមួយម៉ែត្រការ៉េ សម្រាប់អ្នកទោសម្នាក់។ ពន្ធនាគារថ្មី និងបន្ទប់សម្រាប់ដាក់អ្នកទោសបន្តសាងសង់ ប៉ុន្តែវាច្បាស់ណាស់ថាការណ៍នេះមិនគ្រប់គ្រាន់ទេ។

ជាសង្ខេប វិបត្តិនៃភាពចង្អៀតណែនខ្លាំងរបស់អ្នកទោសនៅកម្ពុជា គឺស្ថិតនៅឆ្ងាយពីការដែលអាចដោះស្រាយបាន។ ហើយមកដល់ ឆ្នាំ២០១១ ដំណោះស្រាយនៅតែមិនទាន់ឃើញច្បាស់លាស់នៅឡើយ។

---

[៣] "ស្បែកជាប់ខ្សែភ្លើង [Skin on the Cable]: ការចាប់ខ្លួនដោយខុសច្បាប់ ការឃុំខ្លួនដោយបំពាន និងការធ្វើទារុណកម្ម លើអ្នកប្រើប្រាស់គ្រឿងញៀនក្នុងប្រទេសកម្ពុជា" របាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១០។ អាចរកបាននៅគេហទំព័រ http://www.hrw.org/node/87692.

# ១- ភាពចង្អៀតណែនរបស់អ្នកទោស៖ ការពិនិត្យមើល ឡើងវិញនូវអ្វី ដែលបានកើតឡើង

អង្គការលីកាដូ បានកត់សំគាល់ក្នុងរបាយការណ៍ឆ្នាំ២០១០ថា ប្រព័ន្ធពន្ធនាគារកម្ពុជាទទួលរងនូវការលំបាកដោយកត្តាផ្សំគ្នានៃភាពចង្អៀតណែនយ៉ាងខ្លាំងរបស់អ្នកទោស និងអាគារចាស់ទ្រុឌទ្រោមខ្លាំង។ ស្ថានភាពនេះនៅតែមានដូចគ្នាដដែលនៅក្នុងឆ្នាំ២០១១។

ហេដ្ឋារចនាសម្ព័ន្ធក្នុងផ្នែកខ្លះ ជាពិសេសលើផ្នែកទឹក និងអនាម័យ មានភាពប្រសើរឡើង នៅតាមពន្ធនាគារមួយចំនួន ដោយសារតែមានកិច្ចខិតខំជួយគាំទ្រពីអង្គការអន្តរជាតិនានា ដូចជា ការិយាល័យឧត្តមស្នងការរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា និងគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ។ លើសពីនេះទៀត ចាប់តាំងពីខែកក្កដា ឆ្នាំ២០១០ មក ក៏មានការកសាងបន្តិចបន្តួចបន្ថែមនូវកន្លែងសម្រាប់ដាក់អ្នកទោស។

នៅពន្ធនាគារចំនួន១៨ ដែលឃ្លាំមើលដោយអង្គការលីកាដូ បច្ចុប្បន្ននេះមានអ្នកទោសចំនួន ៧,៥៥៤នាក់ បើប្រៀបធៀបទៅនឹងខែកក្កដា ឆ្នាំ២០១០ ដែលមានចំនួន ៧,១៩៤នាក់។ ការកើនឡើងនៃចំនួនអ្នកទោសនេះ តម្រូវអោយបន្ថែមកន្លែង ចំនួន៧០កន្លែងទៀតសម្រាប់មណ្ឌលអប់រំកែប្រែទី៤ ចំនួន៩០កន្លែង សម្រាប់មណ្ឌលអប់រំកែប្រែទី៣ ចំនួន៥០កន្លែងនៅពន្ធនាគារខេត្តបាត់ដំបង និងចំនួន១៥០កន្លែងត្រូវបំរុងទុកដោយសារមានការសាងសង់ពន្ធនាគារថ្មី នៅខេត្តកំពង់ធំ។

អគ្គនាយកដ្ឋានពន្ធនាគារមិនទាន់បានធ្វើបច្ចុប្បន្នភាពជាផ្លូវការ អំពីលទ្ធភាពដែលផ្ទុកអ្នកទោសបានរបស់ពន្ធនាគារនៅឡើយ ចាប់តាំងអង្គការលីកាដូបានចេញរបាយការណ៍ចុងក្រោយមក។ ប៉ុន្តែដោយផ្អែកតាមព័ត៌មានដែលមាន៖ លទ្ធភាពដែលផ្ទុកអ្នកទោសបានរបស់ពន្ធនាគារនៅទូទាំងប្រទេស គឺស្ថិតនៅក្នុងកំរិត ៨,៣៦០នាក់។ ការប៉ាន់ប្រមាណលើកន្លែងរស់នៅរបស់អ្នកទោសចំនួន ៨,០០០កន្លែង គឺផ្អែកលើការប៉ាន់ប្រមាណចុងក្រោយចាប់តាំងពីពាក់កណ្តាលឆ្នាំ២០១០ របស់អគ្គនាយកដ្ឋានពន្ធនាគារបូកទាំងកន្លែងបន្ថែមនៅឯមណ្ឌលអប់រំកែប្រែទី៣ មណ្ឌលអប់រំកែប្រែទី៤ ពន្ធនាគារខេត្តបាត់ដំបង និងពន្ធនាគារខេត្តកំពង់ធំ ។



*ខាងក្នុងបន្ទប់មណ្ឌលអប់រំកែប្រែទី៤*

ទោះបីជាលទ្ធភាពផ្ទុកអ្នកទោសបានរបស់ពន្ធនាគារបានកើនឡើងសន្សឹមៗ ប៉ុន្តែអ្នកទោសក៏បន្តកើនឡើងនូវចំនួនច្រើនឡើងៗផងដែរ។ គិតមកដល់ថ្ងៃទី២៥ ខែមេសា ឆ្នាំ ២០១១ ពន្ធនាគារទាំងមូលឃុំឃាំងអ្នកទោសសរុបចំនួន១៥,០០១នាក់[៤] គឺ១៧៩% នៃលទ្ធភាពផ្ទុកអ្នកទោសបានរបស់ពន្ធនាគារដែលកំរិតត្រឹមបានតែ ៨,៣៦០នាក់ ប៉ុណ្ណោះ។ អ្នកជាប់ឃុំឃាំងជាបណ្តោះអាសន្នមានចំនួនដល់ទៅ៥,៣៩៤នាក់ នៃចំនួនអ្នកជាប់ឃុំឃាំងទាំងអស់ ឬក៏ ៣៦%។

ទន្ទឹមគ្នានេះដែរ ពន្ធនាគារចំនួន១៨ ដែលឃ្លាំមើលដោយអង្គការលីកាដូ ឃុំឃាំងអ្នកទោសចំនួន ១៣,៦៨១នាក់ (មួយម៉ឺនបីពាន់ប្រាំមួយរយប៉ែតសិបមួយនាក់) គិតមកត្រឹមថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ឬក៏១៨១% នៃលទ្ធភាពផ្ទុកអ្នកទោសបានកំរិតត្រឹម ៧,៥៥៤ នាក់។ ក្នុងខែឧសភា ឆ្នាំ២០១១ យ៉ាងតិចណាស់ មានអ្នកជាប់ឃុំឃាំងជាបណ្តោះអាសន្ន រង់ចាំសវនាការ (ពិរុទ្ធជន) ចំនួន៤,២៩២នាក់ ឬប្រហែលជា ៣១.៤% ក្នុងចំនួន ១៣,៦៨១ នាក់ ដែលជាប់នៅក្នុងពន្ធនាគារ។

ទាំងទិន្នន័យស្តីពីអត្រាឃុំឃាំងអ្នកទោសរបស់ថ្នាក់ជាតិ និងរបស់អង្គការលីកាដូអាចបង្ហាញឲ្យឃើញថាពន្ធនាគារកម្ពុជាស្ថិតក្នុងលំដាប់ខ្ពស់បំផុតទី២៥ នៃពន្ធនាគារដែលមាន

[៤] គេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធនាគារ: ស្ថិតិអ្នកទោសផ្លូវការ គិតមកត្រឹមថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១១ ដែលអាចរកមើលបាននៅគេហទំព័រ http://prison.interior.gov.kh/en/about-prison/2010-12-21-16-12-51

ភាពចង្អៀតណែននៅក្នុងពិភពលោក នេះបើយោងតាមទិន្នន័យដែលចងក្រងឡើងដោយមជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការសិក្សាពីពន្ធនាគារ[៥]។

ក្នុងខែមករា ឆ្នាំ២០១១ គណៈកម្មាធិការប្រឆាំងអំពើទារុណកម្មរបស់អង្គការសហប្រជាជាតិ បានបង្ហាញពីកង្វល់ចំពោះភាពចង្អៀតណែនរបស់អ្នកជាប់ឃុំឃាំងដែលមានលក្ខណៈធ្ងន់ធ្ងរ នៅតាមទីកន្លែងដែលឃុំឃាំងអ្នកដែលត្រូវបានគេដកហូតសេរីភាពរបស់ប្រទេសកម្ពុជា ដែលជាការគំរាមកំហែងដល់សុវត្ថិភាព បូរណភាពរាង្គកាយ និងផ្លូវចិត្ត និងសុខភាពរបស់អ្នកជាប់ឃុំឃាំង..........[និង] ការខ្វះនូវជំរើសផ្សេងនៃទំរង់នៃការដាក់ទណ្ឌកម្មក្រៅពីការឃុំឃាំងក្នុងពន្ធនាគារ[៦]។

## ផលប៉ះពាល់នៃភាពចង្អៀតណែនរបស់អ្នកទោស



*អ្នកទោសរៀបចំអាហារនៅមណ្ឌលអប់រំកែប្រែទី៤៖ បាយគឺជាអាហារគោលក្នុងពន្ធនាគារ បន្លែ និងប្រូតេអ៊ីនគឺមិនគ្រប់គ្រាន់*

ផលប៉ះពាល់អវិជ្ជមាននៃភាពចង្អៀតណែនប្រហែលជាមានការដឹងជាទូទៅ ហើយវានៅតែបាននិយាយរំលឹកឡើងវិញ[៧]: ពន្ធនាគារកម្ពុជា ប្រតិបត្តិការជាមួយនឹងធនធានហេដ្ឋារចនាសម្ព័ន្ធ និងថវិកាមានកំរិតទាបណាស់។ របបម្ហូបអាហាររបស់អ្នកទោសខ្វះជាតិប្រូតេអ៊ីន និងវីតាមីនសមស្រប ទឹកដែលអាចបរិភោគបាន មានការផ្តល់អោយមិនគ្រប់គ្រាន់ ការថែទាំសុខភាពស្ទើរតែគ្មានផ្តល់អោយចំពោះអ្នកទោសទាំងឡាយណាដែលមិនអាចបង់ប្រាក់បាន កម្មវិធីអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជំនាញដែលមាន គឺក្នុងសភាពមិនបិតថេរ។ កន្លែងរស់នៅក្នុងបន្ទប់ពន្ធនាគារមានទំហំតូចចង្អៀត

[៥] ការសិក្សានោះ បច្ចុប្បន្នដាក់ប្រទេសកម្ពុជានៅលំដាប់ទី២៥ ប៉ុន្តែប្រើទិន្នន័យពីឆ្នាំ២០១០។ *សូមអាន* "ពិភពលោកទាំងមូល - អត្រាឃុំឃាំង" របស់មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការសិក្សាពីពន្ធនាគារ ដែលអាចរកមើលបាននៅគេហទំព័រ http://prisonstudies.org/info/worldbrief/wpb_stats.php?area=all&category=wb_occupancy

[៦] សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការប្រឆាំងអំពើទារុណកម្ម ចំពោះរបាយការណ៍លើកទី២ របស់ ប្រទេសកម្ពុជា CAT/C/KHM/២ នាកិច្ចប្រជុំថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០១០ និងបានអនុម័តនាថ្ងៃទី២០ ខែមករា ឆ្នាំ២០១១។ មាននៅគេហទំព័រ http://daccess-dds-ny.un.org/doc/UNDOC/GEN/G11/403/78/PDF/G1140378.pdf?OpenElement

[៧] សម្រាប់ការពិភាក្សាជាបន្ត *សូមអាន* "ភាពចង្អៀតណែននៃពន្ធនាគារ"ដោយ John Howard Society of Alberta មាននៅគេហទំព័រ http://www.johnhoward.ab.ca/pub/C42.htm

ដែលអ្នកទោសខ្លះត្រូវដាក់វេនគ្នាទទួលទានដំណេក។

មានអ្នកទោសកាន់តែច្រើន មានន័យថាមានការផ្តល់អោយកាន់តែតិចទៅៗនូវធនធានដែលពន្ធនាគារមាន។ ប៉ុន្តែនៅក្នុងប្រទេសកម្ពុជាវាមិនមែនមានន័យជាចាំបាច់ថា មានការផ្តល់អោយតិចតួចដល់គ្រប់អ្នកទោសទាំងអស់ដូចៗគ្នានោះទេ។ តាមពិតទៅ ភាពខ្វះខាតបានជួយធ្វើអោយមានការទិញលក់ទំនិញ និងធនធានដែលមាននៅស្ទើរគ្រប់ពន្ធនាគារទាំងអស់ដែលយើងសឹងតែមិននឹកស្មានដល់ ដូចជា ថ្នាំសង្កូវ កន្លែងទទួលទានដំណេក ពេលវេលាលំហែ សិទ្ធិទទួលការសួរសុខទុក្ខ។ល។ អ្នកទោសក្រីក្រមានបន្ទុកធ្ងន់ធ្ងរនៅក្នុងពន្ធនាគារដែលត្រូវចំណាយស្ទើរគ្រប់អ្វីៗទាំងអស់។ អ្នកទោសដែលមិនមានថវិកាគ្រប់គ្រាន់ដែលមិនបានទទួល "សិទ្ធិទាំងអស់នេះ" តែងតែរស់នៅក្នុងលក្ខខ័ណ្ឌមិនស្មើភាពជាមួយអ្នកឯទៀត។ អ្នកទោសដែលជាអ្នកមានទ្រព្យសម្បត្តិ និងមានខ្នងបង្អែក អាចមានបន្ទប់ឯកជន ដែលមានគ្រែ កង្ហារ ទូរទឹកកក និងម្ហូបអាហារបន្ថែម ការថែទាំសុខភាពជាឯកជន និងទទួលប្តី ឬប្រពន្ធដែលមកសួរសុខទុក្ខ ព្រមទាំងសេវាសំខាន់ៗផ្សេងទៀត។

ភាពចង្អៀតណែនរបស់អ្នកទោសក៏ប៉ះពាល់ផងដែរលើលក្ខខណ្ឌអនាម័យ និងសុខភាព។ នៅក្នុងពន្ធនាគារខ្លះ ប្រព័ន្ធអនាម័យចូលដល់ដំណាក់កាលនៃកម្រិតកំណត់របស់ខ្លួន ហើយទឹកមិនស្អាតបានហូរហៀរចេញទៅទីកន្លែងដែលប្រើរួមគ្នា។ ប្រព័ន្ធទឹកប្រើប្រាស់ (ដែលមានសភាពអត្តខាត់ និងមិនគួរជឿទុកចិត្តបានស្រាប់នោះ) មានសម្ពាធត្រូវផ្គត់ផ្គង់លើសចំនួនដល់ទៅពីរ ឬបីដងនៃចំនួនអ្នកទោសដែលប្រព័ន្ធនេះអាចបំពេញបាន។ បញ្ហានេះមិនត្រឹមតែនាំអោយខ្វះទឹកបរិភោគប៉ុណ្ណោះទេ ប៉ុន្តែខ្វះទឹកសម្រាប់ប្រើប្រាស់ផ្សេងទៀតផងដែរ។ ដោយសារតែភាពខ្វះខាតទឹកនៅពន្ធនាគារមួយ អ្នកស្រាវជ្រាវរបស់អង្គការលីកាដូ បានឃើញអ្នកទោសខ្លះ ស្រោចដំណាំរបស់ពន្ធនាគារជាមួយនឹងទឹកលូ។

ខណៈដែលអ្នកទោសរស់នៅជាមួយគ្នាយ៉ាងជិតនិងចង្អៀតគ្នា បណ្តាលអោយមានការរីករាលដាលនៃជំងឺឆ្លងដូចជា របេង និងរមាស់។ ជំងឺទាំងពីរនេះ គឺជាបញ្ហាធ្ងន់ធ្ងរដែលកើតមាននៅតាមពន្ធនាគាររបស់ប្រទេសកម្ពុជា។ ម្យ៉ាងវិញទៀតការខ្វះខាតនៃជីវជាតិអាហារ និងទឹកស្អាតក៏ជាមូលហេតុដែលនាំអោយមានផលប៉ះពាល់ដល់ស្ថានភាពសុខភាពអ្នកទោសផងដែរ។ ការបែងចែកទំហំកន្លែងរស់នៅដែលមានកំណត់ និងការប្រកួតប្រជែងគ្នាដើម្បីទទួលបានផលប្រយោជន៍មកប្រើប្រាស់ ក៏ធ្វើអោយកើនឡើងនូវជំងឺថប់បារម្ភ (stress) ដែលអាចមានផលប៉ះពាល់ដល់សុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់អ្នកទោសផងដែរ។

ជាចុងក្រោយគឺ ភាពចង្អៀតណែនរបស់អ្នកទោស ធ្វើអោយមានការលំបាកខ្លាំងថែមទៀត ដល់មន្ត្រីពន្ធនាគារក្នុងការបំពេញការងាររបស់ពួកគេតាំងពីការគ្រប់គ្រងអ្នកទោសដែលពិបាកគ្រប់គ្រងដើម្បីធានាសុវត្ថិភាពពន្ធនាគារ រហូតដល់ការផ្ដល់នូវកម្មវិធីនានាសម្រាប់អ្នកទោស។ ភាពចង្អៀតណែនរបស់អ្នកទោស គឺជាកត្តាមួយក្នុងចំណោមកត្តាជាច្រើនដែលរួមចំនែកដល់ការប្រើប្រាស់គណៈកម្មការដែលគេហៅថា គណៈកម្មការស្វ័យគ្រប់គ្រង ដើម្បីគ្រប់គ្រងលើចំនួនអ្នកទោសទាំងអស់។ គណៈកម្មការនេះបានរៀបចំឡើងនិងដាក់ឈ្មោះសារជាថ្មីនាពេលថ្មីៗដោយអគ្គនាយកដ្ឋានពន្ធនាគារ ហើយដែលមានសមាសភាពដូចជាអ្នកទោសដ៏ទៃផ្សេងទៀតដែរ និងត្រូវបានគេជ្រើសរើសឡើងដើម្បីអោយទទួលនូវសិទ្ធិនានា ចំពោះការមើលខុសត្រូវលើអ្នកទោសដទៃទៀតអោយគោរពតាមបទបញ្ជាដែលបានកំណត់។ អ្នកទោសដែលត្រូវបានសម្ភាសន៍ដោយអង្គការលីកាដូនិយាយថា ភារកិច្ចមិនផ្លូវការរបស់គណៈកម្មការនេះ អាចមាន ទាំងការវាយដំលើអ្នកទោសផ្សេងទៀត ជំនួសអោយអនុរក្សពន្ធនាគារ។[៨]

## ‘យុទ្ធសាស្ត្រដែលមិនទទួលបានជោគជ័យ’

ក្នុងឆ្នាំ២០១០ អង្គការលីកាដូ បានកត់សំគាល់ថា រដ្ឋាភិបាលមានបំណងដោះស្រាយបញ្ហានៃភាពចង្អៀតណែនរបស់អ្នកទោសតាមវិធីមួយ គឺការសាងសង់ពន្ធនាគារថ្មី ហើយដែលវិធីនេះ គឺជាយុទ្ធសាស្ត្រមួយដែលមិនទទួលបានជោគជ័យទេ។ ទិន្នន័យតាំងពីពេលនោះ មកបានគាំទ្រដល់ការសង្ស័យនេះ។ ប្រទេសកម្ពុជានឹងមិនអាចធ្វើអោយចេញផុតពីវិបត្តិបច្ចុប្បន្ននៃភាពចង្អៀតណែនរបស់អ្នកទោសបានទេ។ បញ្ហានេះមានវិសាលភាពធំធេងណាស់ ហើយវាកំពុងតែរីកកាន់តែធំឡើងៗ។

តារាងខាងក្រោមបង្ហាញពីលទ្ធភាពផ្ទុកអ្នកទោសបាន និងតួលេខអ្នកទោសនៅពន្ធនាគារចំនួន១៨ ដែលឃ្លាំមើលដោយអង្គការលីកាដូ។ តារាងបង្ហាញតួលេខអ្នកទោសក្នុងខែមិថុនា ឆ្នាំ២០១០ (ដកស្រង់ចេញពីរបាយការណ៍លើកមុនរបស់អង្គការលីកាដូ) និង

---

[៨] របាយការណ៍រួម អង្គការក្រៅរដ្ឋាភិបាលប្រទេសកម្ពុជា ស្ដីពីអំពើទារុណកម្ម និងការប្រព្រឹត្តិបែបឃោរឃៅ អមនុស្សធម៌ ឬការប្រព្រឹត្តិបែបបន្ទាបបន្ថោក ឬបែបទណ្ឌកម្មដទៃទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា (ដាក់ជូនគណៈកម្មាការប្រឆាំងអំពើទារុណកម្មអង្គការសហប្រជាជាតិ មុនការដាក់ជូនរបាយការណ៍លើកទី២ របស់ប្រទេសកម្ពុជា នៅឯកិច្ចប្រជុំលើកទី៤៥ របស់គណៈកម្មាការប្រឆាំងអំពើទារុណកម្ម) ខែតុលា ឆ្នាំ២០១០ វាក្យខ័ណ្ឌ ៥៣ មាននៅគេហទំព័រ http://www2.ohchr.org/english/bodies/cat/docs/ngos/Joint_Cambodian_NGO_Report_Cambodia45.pdf។ អាជ្ញាធរពន្ធនាគារអះអាងថាពួកគេបាន "ឈប់ដំណើរការ" ជាផ្លូវការនូវគណៈកម្មការស្វ័យគ្រប់គ្រងនៅដើមឆ្នាំ2011 ហើយឈ្មោះ និងរចនាសម្ព័ន្ធនៃគណៈកម្មការនេះនៅតាមពន្ធនាគារមួយចំនួនបានផ្លាស់ប្ដូររួចហើយ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏នៅតែមានរបាយការណ៍ស្ដីពីអំពើរំលោភ ហើយសមាជិកគណៈកម្មការនេះនៅតាមពន្ធនាគារមួយចំនួននៅតែកំណត់បានតាមរយៈប្លង់ដៃពិសេសរបស់ពួកគេ។

ក្នុងខែឧសភា ឆ្នាំ២០១១ជាតួលេខអ្នកទោសដែលមានថ្មីៗបំផុត។ ជាក់ស្តែងបច្ចុប្បន្ននេះ ភាពចង្អៀតណែនមានសភាពខ្លាំងជាង កាលពីមួយឆ្នាំកន្លងទៅ។

## លទ្ធភាពផ្ទុកអ្នកទោសបានតាមពន្ធនាគាររបស់ប្រទេសកម្ពុជា

| ពន្ធនាគារ | ទំហំផ្ទុកអ្នកទោសបាន (ខែមិថុនា ឆ្នាំ២០១០) | ចំនួនអ្នកទោស (ខែមិថុនា ឆ្នាំ២០១០) | ចំនួនអ្នកទោស (ខែឧសភា ឆ្នាំ២០១១) | ភាគរយនៃទំហំផ្ទុក (ខែឧសភា ឆ្នាំ២០១១) |
|---|---|---|---|---|
| ប៉េហ្ស៊ី[៩] | ២០០ | ១៦៧ | ១៤២ | ៧១% |
| ម១ | ១៦០០ | ២៦៤៤ | ២៨៤៨ | ១៧៨% |
| ម២ | ៣០០ | ៧៧៧ | ៨១១ | ២៧០.៣% |
| ម៣ | ៨១០[១០] | ១៥២៩ | ១៥០២ | ២០៨.៦% |
| ម៤ | ២១០[១១] | ១៥៤ | ១៩៦ | ៩៣.៣% |
| តាខ្មៅ | ៣១៤ | ១០៤២ | ១០៤០ | ៣៣១.២% |
| ព្រះសីហនុ | ១៥០ | ៣៣២ | ៤៣៥ | ២៩០% |
| កំពង់ស្ពឺ | ១៨០ | ៣១៣ | ៣៣៨ | ១៨៧.៨% |
| កំពត | ១៦០ | ៣៤៥ | ៤២៨ | ២៦៧.៥% |
| កំពង់ឆ្នាំង | ១៥០ | ២៧១ | ៣៣៦ | ២២៤% |
| កំពង់ចាម | ៥០០ | ៧៩៨ | ៨៣៩ | ១៦៧.៨% |
| កំពង់ធំ | ២០០[១២] | ២០៨ | ២៧១ | ១៣៥.៥% |
| កោះកុង | ១៥០ | ២១៨ | ២៣៧ | ១៥៨% |
| ពោធិ៍សាត់ | ១២០ | ២២៩ | ២៣៣ | ១៩៤.២% |

[៩] អ្នកទោសដែលត្រូវបានសម្ភាសន៍ដោយអង្គការលីកាដូ បានចង្អុលបង្ហាញថា ប៉េហ្ស៊ី ជាពន្ធនាគារតែមួយគត់ស្ថិតនៅក្រោមកម្រិតលទ្ធភាពផ្ទុកទៅទៀតនោះ ត្រូវបានគេដឹងជាទូទៅថាជា "ពន្ធនាគារបង់ថ្លៃសម្រាប់ស្នាក់នៅ"។ ការណ៍នេះ អាចពន្យល់បានពីអត្រានៃការឃុំឃាំងទាបជាប្រចាំរបស់ពន្ធនាគារនេះ។

[១០] ចំនួននេះឆ្លុះបញ្ចាំងពីកន្លែងបន្ថែមចំនួន៩០ ដែលបានថែមតាំងពីខែកក្កដា ឆ្នាំ២០១០មក។

[១១] ចំនួននេះឆ្លុះបញ្ចាំងពីកន្លែងបន្ថែមចំនួន៧០ ដែលបានថែមតាំងពីខែកក្កដា ឆ្នាំ២០១មក។

[១២] ចំនួននេះឆ្លុះបញ្ចាំងពីកន្លែងបន្ថែមចំនួន១៥០ ដែលបានថែមតាំងពីខែកក្កដា ឆ្នាំ២០១០មក តាមរយៈការបញ្ចប់ការសាងសង់ពន្ធនាគារថ្មី។ អតីតពន្ធនាគារខេត្តកំពង់ធំ ជាសំណង់បុរាណបែបអាណានិគមមានវ័យជិត១00ឆ្នាំ ឥឡូវនេះបានបិទហើយ។

| | | | | |
|---|---|---|---|---|
| បាត់ដំបង | ៦៥០[១៣] | ១១៧៤ | ១១៩១ | ១៩០.២% |
| បន្ទាយមានជ័យ | ៧០០ | ៨១៦ | ១០៨៥ | ១៥៥% |
| សៀមរាប | ១០០០ | ១៣៦១ | ១៤៨២ | ១៤៨.២% |
| ស្វាយរៀង | ១៦០ | ២៦៦ | ៣១៧ | ១៩៨.១% |
| **សរុប** | **៧៥៥៤[១៤]** | **១២៦៩៦** | **១៣៦៨១** | **១៨១.១%** |

**ទិន្នន័យមិនត្រឹមត្រូវនៃលទ្ធភាពផ្ទុកអ្នកទោសបានរបស់ពន្ធនាគារៈ ភាពចង្អៀតណែន ហាក់ដូចជាមានសភាពកាន់តែខ្លាំងឡើងៗជាងអ្វីដែលយើងសន្និដ្ឋាន**

អត្រាឃុំឃាំងមានក្នុងតារាងខាងលើ បង្ហាញនូវស្ថានភាពដ៏គួរអោយព្រួយបារម្ភណាស់ទៅហើយ ប៉ុន្តែអត្រាឃុំឃាំងទាំងនេះហាក់ដូចជាមានភាពធ្ងន់ធ្ងរ នៅពេលដែលពិនិត្យមើលយ៉ាងជិតដល់ លើការគណនាពីលទ្ធភាពផ្ទុកអ្នកទោសបានរបស់ពន្ធនាគារប្រទេសកម្ពុជា។ អគ្គនាយកដ្ឋានពន្ធនាគារមិនទាន់បានដឹកនាំការសិក្សាដោយពេញលេញនៅទូទាំងប្រទេសលើលទ្ធភាពផ្ទុកអ្នកទោសបានរបស់ពន្ធនាគារនៅឡើយ ហើយក៏មិនទាន់បានកំណត់ជាសាធារណៈអំពីបទដ្ឋានទំហំសម្រាប់ដាក់អ្នកទោសម្នាក់នោះដែរ។ ជាទូទៅលទ្ធភាពដែលផ្ទុកអ្នកទោសបានរបស់ពន្ធនាគារនៅកម្ពុជាមានភាពប្រែប្រួល មានន័យថាការប៉ាន់ប្រមាណអំពីលទ្ធភាពដែលអាចផ្ទុកអ្នកទោសបាន ជួនកាលលើសពីការពិត ជួនកាលប្រហាក់ប្រហែលនឹងការពិត។

ពន្ធនាគារខេត្តបន្ទាយមានជ័យ ជាឧទាហរណ៍ត្រូវបានវាយតម្លៃថាមានលទ្ធភាពផ្ទុកអ្នកទោសបាន៧០០នាក់[១៥]។ ក្នុងអំឡុងពេលនៃទស្សនកិច្ចទៅកាន់ពន្ធនាគារនោះក្នុងខែឧសភា ឆ្នាំ២០១១ អង្គការលីកាដូបានរកឃើញចំនួនអ្នកទោសសរុបមានលើសពី១,០០០នាក់។ ស្ថានភាពនេះ ធ្វើអោយអត្រាឃុំឃាំងជាផ្លូវការមានកំរិតប្រហែល១៥៥% ដែលវាស្ថិតក្នុងកំរិតទាបចុងក្រោយគេនៃតួលេខដែលបានរៀបរាប់ក្នុងតារាងខាងលើ។ ទោះបីជាយ៉ាងណាក៏ដោយ បើមើលទៅលើលក្ខខណ្ឌនៃបន្ទប់ឃុំឃាំងវិញ ឃើញថាមានភាពខុសគ្នា

[១៣] ចំនួននេះឆ្លុះបញ្ចាំងពីកន្លែងបន្ថែមចំនួន៥0 ដែលបានថែមតាំងពីខែកក្កដា ឆ្នាំ២០១0មក។

[១៤] អគ្គនាយកដ្ឋានពន្ធនាគារក៏មានគម្រោងពង្រីកពន្ធនាគារ ម១ ម៤ កំពង់ចាម និងពន្ធនាគារដទៃទៀតដែលមិនស្ថិតក្រោមការឃ្លាំមើលរបស់អង្គការលីកាដូ។ មានផែនការផ្លាស់ប្តូរទីតាំងពន្ធនាគារ ខេត្តពោធិ៍សាត់ ព្រៃវែង តាកែវ និងរតនគីរី និងផែនការសាងសង់ពន្ធនាគារថ្មីនៅប៉ៃលិន និងឧត្តរមានជ័យ។ អគ្គនាយកដ្ឋានពន្ធនាគារមិនបានប្រាប់អោយដឹងពីកាលបរិច្ឆេទ ប៉ាន់ស្មាននៃការបញ្ចប់គម្រោងដទៃទៀតទេ ប៉ុន្តែគម្រោងជាច្រើនហាក់ដូចជាត្រូវការពេលវេលាច្រើនឆ្នាំទៅមុខទៀត។ *សូមអាន* "របាយការណ៍អំពីការងារសំរេចបានក្នុងឆ្នាំ២០១០ និងផែនការសម្រាប់ឆ្នាំ២០១១" របស់អគ្គនាយកដ្ឋានពន្ធនាគារ ផ្សព្វផ្សាយ ក្នុងខែមករា ឆ្នាំ២០១១។

[១៥] តួលេខនេះត្រូវបានយកចេញមកពីការប៉ាន់ប្រមាណផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធនាគារ ប៉ុន្តែបុគ្គលិកបាន យល់ថាចំនួន ៤២០-៤៥០នាក់ ជាតួលេខនៃលទ្ធភាពផ្ទុកដែលសមស្របជាង។ តាមពិត តួលេខអាចទាបជាងនេះទៅទៀត។

យ៉ាងខ្លាំង។ អ្នកទោសប្អូនដប់នាក់ទទួលទានដំណោកតាមផ្លូវដើរមុខបន្ទប់ឃុំឃាំង ចំនួនមន្ត្រីពន្ធនាគារធៀបទៅនឹងចំនួនអ្នកទោស គឺដល់កំរិតកំណត់របស់ខ្លួន ហើយពន្ធនាគារប្រកបទៅដោយភាពចង្អៀតណែនដ៏គ្រោះថ្នាក់។

វាច្បាស់ណាស់ថា ពន្ធនាគារពិតជាមិនមានលទ្ធភាពផ្ទុកអ្នកទោសអោយបានសមស្រប ដើម្បីឃុំឃាំងអ្នកទោសត្រឹមតែ ៧០០នាក់ទេ ហើយការវាស់វែងទំហំបន្ទប់ឃុំឃាំងនាំអោយបញ្ជាក់ពីការអះអាងនេះ។ បន្ទប់ឃុំឃាំងក្នុងអាគារដែលអង្គការលីកាដូ បានទៅធ្វើទស្សនកិច្ច គឺមានទំហំ ១៦ម៉ែត្រការ៉េ។ ខណៈដែលមិនមានបទដ្ឋានអន្តរជាតិកំណត់ពីទំហំដែលត្រូវផ្តល់អោយសម្រាប់អ្នកទោសម្នាក់ៗ តែមានគោលការណ៍ណែនាំមួយចំនួនដូចជាគណៈកម្មការអឺរ៉ុបសម្រាប់ការទប់ស្កាត់អំពើទារុណកម្មបានផ្តល់អនុសាសន៍ថា អ្នកទោសម្នាក់ៗត្រូវទទួលបានទំហំយ៉ាងតិចណាស់ក៏ ៤ម៉ែត្រការ៉េ ដែរ នៅក្នុងបន្ទប់ឃុំឃាំងដែលដាក់អ្នកទោសឯទៀតច្រើននាក់[១៦]។ គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិបានថ្លែងថា "សូម្បីតែ នៅក្នុងស្ថានភាពមានវិបត្តិជាពិសេសក៏ដោយ ក៏ទំហំកន្លែងក្នុងបន្ទប់ឃុំឃាំង និងកន្លែងទទួលទានដំណោកសំរាប់បុគ្គលម្នាក់មិនត្រូវមានទំហំតិចជាង ២ម៉ែត្រការ៉េឡើយ។"[១៧]

នៅពន្ធនាគារខេត្តបន្ទាយមានជ័យ បន្ទប់ឃុំឃាំងទំហំ១៦ម៉ែត្រការ៉េ ដាក់អ្នកទោសរវាង ២០ និង ២២នាក់ ដែលមានន័យថា អ្នកទោសម្នាក់ៗមានទំហំកន្លែងតែ ០.៧៣ម៉ែត្រការ៉េប៉ុណ្ណោះ។ លទ្ធភាពផ្ទុកអ្នកទោសដែលសមស្រប គឺរវាង ៤ និង ៨នាក់ សម្រាប់បន្ទប់ឃុំឃាំងមួយ (ចំនួនអាចតិចជាងនេះបន្តិចដោយសារថាការវាស់វែងបន្ទប់ឃុំឃាំង គឺត្រូវតែវាស់រួមទាំងបង្គន់ និងទីកន្លែងងូតទឹក) ដែលវាមានទំហំរហូតដល់ទៅ ៣ម៉ែត្រការ៉េ ដែលជាទីកន្លែងមិនអាចប្រើប្រាស់សម្រាប់ទទួលទានដំណោកបាន)។ តាមការប៉ាន់ប្រមាណដែលត្រឹមត្រូវ គឺបន្ទប់ឃុំឃាំងជាក់ស្តែងបានដាក់អ្នកទោសពី ៥៥០% ទៅ ២៧៥% នៅក្នុងលទ្ធភាពដែលផ្ទុកអ្នកទោសបាន។

[១៦] គេហទំព័រ http://www.coe.int/t/commissioner/Viewpoints/070305_en.asp

[១៧] គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ "ទឹក ប្រព័ន្ធអនាម័យ អនាម័យខ្លួនប្រាណ និងកន្លែងរស់នៅ នៅក្នុងពន្ធនាគារ" ខែសីហា ឆ្នាំ២០០៥ ទំព័រ២១។

## រូបភាពតំណាងបង្ហាញពីចំនួនអ្នកទោស និងភាពចង្អៀតណែនក្នុងពន្ធនាគារ
## (ទិន្នន័យខែមេសា ឆ្នាំ២០១១)





*បន្ទប់អ្នកទោសបុរស នៅពន្ធនាគារខេត្តកំពង់ឆ្នាំង*

តួលេខនៃលទ្ធភាពដែលផ្ទុកអ្នកទោសបាននៅពន្ធនាគារខ្លះ ហាក់ដូចជាស្ទើរតែដូចនឹងស្ថានភាពជាក់ស្តែង។ ឧទាហរណ៍ បន្ទប់ឃុំឃាំងទំហំ ៨៥ម៉ែត្រការ៉េនៅពន្ធនាគារតាខ្មៅ នាពេលថ្មីៗនេះ មានផ្ទុកអ្នកទោសចំនួន ៩៧នាក់ ដែលគិតទៅអ្នកទោសម្នាក់ៗទទួលបានត្រឹមតែទំហំ ០.៨៨ ម៉ែត្រការ៉េប៉ុណ្ណោះ។ បន្ទប់ឃុំឃាំងនេះដែលសមស្របបំផុតគួរតែដាក់អ្នកទោសត្រឹមតែ ២១ ទៅ ៤២នាក់ប៉ុណ្ណោះ ដែលមានន័យថា លទ្ធភាពផ្ទុកឡើងដល់ទៅ៤៦២% ទៅ២៣១% លើលទ្ធភាពដែលផ្ទុកអ្នកទោសបាន។ ប៉ុន្តែលទ្ធភាពផ្ទុក និងអត្រាឃុំឃាំងផ្លូវការណ៍របស់ពន្ធនាគារតាខ្មៅ ឆ្លុះបញ្ចាំងស្ថានភាពពិតនេះ: យោងតាមស្ថិតិអង្គការលីកាដូ ពន្ធនាគារទាំងមូលផ្ទុកអ្នកទោសដល់ទៅ ៣៣១% នៃលទ្ធភាពផ្ទុកជាផ្លូវការ។

លទ្ធភាពដែលផ្ទុកអ្នកទោសបាននៅពន្ធនាគារម៤ ក៏ស្របតាមបទដ្ឋាននៃទំហំកន្លែង ២ម៉ែត្រការ៉េ សម្រាប់អ្នកទោសម្នាក់ៗផងដែរ ថ្វីត្បិតតែការប៉ាន់ប្រមាណបានគិតទាំងលើទំហំកន្លែងទាំងអស់ ដោយគិតរួមទាំងទីកន្លែងសម្រាប់ទទួលទានដំណេកមិនបានដូចជា ច្រកដើរ និងបង្គន់។

នាពេលបច្ចុប្បន្ននេះ នៅតែមិនទាន់បានដឹងអំពីលទ្ធភាពដែលផ្ទុកអ្នកទោសបានពិតប្រាកដរបស់ពន្ធនាគារកម្ពុជាទាំងអស់នៅឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ អ្វីដែលប្រាកដ គឺតួលេខបច្ចុប្បន្ន ៨,៣៦០នាក់ ហាក់ដូចជាលើសពីការប៉ាន់ស្មាន។ ហើយថាតើវាលើសពីការប៉ាន់ស្មានយ៉ាងដូចម្តេចនោះនឹងនៅតែអាចអោយមើលឃើញជាបន្តទៀត ប៉ុន្តែជាឧទាហរណ៍ បើទោះបីមានការថយចុះ២៥% នៃតួលេខនៃលទ្ធភាពដែលផ្ទុកអ្នកទោសបាន ក៏នៅតែឃើញថាពន្ធនាគារប្រទេសកម្ពុជាបានផ្ទុកអ្នកទោសដល់ទៅ ២៤០% នៃលទ្ធភាពដែលផ្ទុកអ្នកទោសបានដដែល។

អង្គការលីកាដូសូមសំណូមពរដល់អគ្គនាយកដ្ឋានពន្ធនាគារ សូមមេត្តាដឹកនាំការសិក្សាជាបន្ទាន់មួយ លើពន្ធនាគារទាំងអស់នៅទូទាំងប្រទេសដែលអាចធ្វើទៅបានជាមួយនឹងជំនួយពីដៃគូរអន្តរជាតិ ដើម្បីគណនាទំហំដែលផ្ទុកអ្នកទោសបានពិតប្រាកដរបស់ពន្ធនាគារ។ យើងខ្ញុំជឿជាក់ថាការសិក្សានេះនឹងនាំអោយមានការកំណត់បានច្បាស់ជាបន្តទៀតពីភាពធ្ងន់ធ្ងរនៃវិបត្តិចង្អៀតណែនខ្លាំង និងពីភាពបន្ទាន់នៃបញ្ហាដែលនឹងត្រូវរិះរកដំណោះស្រាយបែបណា។

### ចំនួនអ្នកទោស: ថ្វីត្បិតឃើញថាមានការកើនឡើងយឺតមែន ក៏ប៉ុន្តែនៅតែច្រើនហួស

ថ្វីត្បិតតែយើងទទួលព័ត៌មានមិនប្រក្រតីយ៉ាងណាក៏ដោយ ក៏មាននូវចំណុចវិជ្ជមានមួយចាប់តាំងពីខែកក្កដា ឆ្នាំ២០១០ មក: កំណើនអ្នកទោសបានថយចុះមកវិញបន្តិចបន្តួច។ ពន្ធនាគារទាំង១៨ ដែលឃ្លាំមើលដោយអង្គការលីកាដូ មានកំណើនអ្នកទោសប្រចាំឆ្នាំជាមធ្យមគឺ ១២.៩% តាំងពីខែធ្នូ ឆ្នាំ២០០៤ មកដល់បច្ចុប្បន្ន។ កំណើននេះទាបជាងកំណើនរយៈពេល៥ឆ្នាំ ក្នុងកម្រិតមធ្យមគឺ ១៤.២% ដែលអង្គការលីកាដូ បានសរសេរចងក្រងក្នុងរបាយការណ៍ខែកក្កដា ឆ្នាំ២០១០។

ភាពប្រសើរឡើងនេះ មួយផ្នែក គឺអាស្រ័យលើចំនួនអ្នកទោសនៅពន្ធនាគារទាំង១៨ ដែលឃ្លាំមើលដោយអង្គការលីកាដូ ជាក់ស្តែង*ថយចំនួន* ដោយការធ្វើប្រភាគនៃចំនួនអ្នកទោសក្នុងរវាងខែកក្កដា និងខែធ្នូ ឆ្នាំ២០១០។ កំណើនសម្រាប់ពន្ធនាគារនៅទូទាំងប្រទេសក្នុងឆ្នាំ២០១០ មានកម្រិត ៥.២% និងមានកម្រិត ២.៦% ចំពោះពន្ធនាគារដែលឃ្លាំមើលដោយអង្គការលីកាដូ។

កំណើនទាំងនេះ គឺជាតួលេខគួរអោយមានសង្ឃឹម បើសិនជាមិនមែនជាការពិតដែលថា កំណើនមានសន្ទុះចាប់តាំងពីចុងឆ្នាំ២០១០ មក។ នៅទូទាំងប្រទេស ចំនួនអ្នកទោសតាមពន្ធនាគារកើនឡើង ៨.៦% ត្រឹមតែក្នុងរយៈពេល៥ខែដំបូងនៃឆ្នាំ២០១១។ ពន្ធនាគារដែលឃ្លាំមើលដោយអង្គការលីកាដូ ឃើញមានកំណើន ៩% ក្នុងកំឡុងពេលដូចគ្នានេះ។ កំណើនចុងក្រោយ បណ្តាលមកពីការកើនឡើងនៃចំនួនអ្នកទោសសរុបទាំងអស់នៅទូទាំងប្រទេសគឺ ១២.៦% រវាងខែមីនា ឆ្នាំ២០១០ និងខែមេសា ឆ្នាំ២០១១។

សូម្បីតែចំនួន ១២.៦% ក៏ជាតួលេខដែលមានភាពប្រសើរឡើងបន្តិចដែរ សម្រាប់មធ្យមភាគរយៈពេលវែង ប៉ុន្តែកំណើននៅតែមានកម្រិតខ្ពស់ខ្លាំងសម្រាប់រាជរដ្ឋាភិបាលដែលត្រូវដោះស្រាយកន្លែងស្នាក់នៅរបស់អ្នកទោស តាមរយៈការសាងសង់ពន្ធនាគារថ្មីតែមួយមុខនោះ។ មិនមានប្រព័ន្ធពន្ធនាគារណាដែលអាចបន្ថែមកន្លែងស្នាក់នៅសម្រាប់ផ្ទុកអ្នកទោស ដែលមានកំណើន ១៣% ក្នុងមួយឆ្នាំបានទេ ដោយមិនគិតពីប្រព័ន្ធពន្ធនាគាររបស់ប្រទេសកម្ពុជា ដែលជាប្រព័ន្ធមួយខ្វះខាតធនធានយ៉ាងខ្លាំង ហើយដែលប្រតិបត្តិការលើសពីលទ្ធភាពដែលផ្ទុកអ្នកទោសបានជិតពីរដង។

របាយការណ៍ឆ្នាំ២០១០ របស់អង្គការលីកាដូ មានដាក់បញ្ចូលតារាងដែលបង្ហាញពីអត្រាកំណើនប៉ាន់ប្រមាណទាំងលើចំនួនអ្នកទោសទាំងអស់ និងលើទំហំដែលផ្ទុកអ្នកទោសបាន។ តារាងបង្ហាញ នូវអត្រាកំណើនប៉ាន់ប្រមាណចំនួនអ្នកទោស គឺ ៥% ១០% និង ១៥% (មធ្យមភាគសម្រាប់រយៈពេល ៥ឆ្នាំនាពេលនោះ) ជាមួយគ្នានឹងការប៉ាន់ប្រមាណបីលើការកើនឡើងនូវទំហំដែលផ្ទុកអ្នកទោសបានរបស់កន្លែងទទួលទានដំណេកគឺ ៥០០ កន្លែង ១,០០០កន្លែង និង២,៥០០កន្លែង[១៨] ក្នុងមួយឆ្នាំ។

តារាងខាងក្រោម គឺបច្ចុប្បន្នភាពនៃការគណនាក្នុងរបាយកាណ៍មុនរបស់អង្គការលីកាដូ បង្ហាញទិន្នន័យជាក់ស្តែងសម្រាប់ឆ្នាំ២០១១ និងការប៉ាន់ប្រមាណរហូតដល់ឆ្នាំ២០១៥។ យើងក៏បានកែសម្រួលតួលេខ២ គឺ: (១) ការប៉ាន់ប្រមាណចុងក្រោយលើកំណើនចំនួនអ្នកទោសទាំងអស់ដោយបញ្ចុះពី ១៥% ទៅ ១៣% វិញ ដើម្បីអោយឆ្លុះបញ្ចាំងពីមធ្យមភាគរយៈពេល៦ឆ្នាំថ្មីៗនេះ និង (២) ការប៉ាន់ប្រមាណលើកដំបូងលើការកើនឡើង

[១៨] តួលេខ ២,៥០០ តំណាងអោយចំនួននៃកន្លែងដែលបានគ្រោងឡើងសម្រាប់ពន្ធនាគារធំថ្មីរបស់អគ្គនាយកដ្ឋានពន្ធនាគារ គឺមណ្ឌលអប់រំកែប្រែទី៤ ដែលនៅទីនោះមានអ្នកទោសរស់នៅតាមផ្នែកខ្លះរួចហើយ ប៉ុន្តែបច្ចុប្បន្ននេះ នៅតែកំពុងសាងសង់បន្ត។ បន្ទាប់ពីការសាងសង់បានជាង ១៨ខែមក ពន្ធនាគារនេះមានលទ្ធភាពផ្ទុកត្រឹមតែ ២១០នាក់ ប៉ុណ្ណោះ។ ភាពរីកចម្រើនយ៉ាងយឺតនៅ ម៤ គូសបញ្ជាក់ពីលទ្ធភាពមិនអាចទៅរួចតែរហូតមក របស់អគ្គនាយកដ្ឋានពន្ធនាគារ ដើម្បីបន្ថែមកន្លែងអោយបានជិតដល់ចំនួន ២,៥០០កន្លែងក្នុងមួយឆ្នាំ។

នៃទំហំដែលផ្ទុកអ្នកទោសបានដោយបញ្ចុះពី ៩០០កន្លែង ទៅ ៣៩០កន្លែងវិញ ដើម្បីអោយឆ្លុះបញ្ចាំងពីមធ្យមភាគរយៈពេល ៦ឆ្នាំថ្មីៗនេះ។

| ឆ្នាំ | ទំហំដែលផ្ទុកអ្នកទោសបានកើនឡើងដោយកើនកន្លែងថ្មី ៣៩០ ក្នុង១ឆ្នាំ (អត្រាបច្ចុប្បន្ន) | ទំហំដែលផ្ទុកអ្នកទោសបានកើនឡើងដោយកើនកន្លែងថ្មី ១,០០០ ក្នុង១ឆ្នាំ | ទំហំដែលផ្ទុកអ្នកទោសបានកើនឡើងដោយកើនកន្លែងថ្មី ២,៥០០ ក្នុង១ឆ្នាំ (មថ) | កំណើនប្រចាំឆ្នាំ របស់អ្នកទោស នៅអត្រា ៥% | កំណើនប្រចាំឆ្នាំ របស់អ្នកទោសនៅអត្រា ១០% | កំណើនប្រចាំឆ្នាំរបស់អ្នកទោសនៅអត្រា ១៣% (មធ្យមភាគរយៈពេល៦ឆ្នាំថ្មីៗ) |
|---|---|---|---|---|---|---|
| ២០១១ | ៨,៣៦០ | ៨,៣៦០ | ៨,៣៦០ | ១៥,០០១ | -- | -- |
| ២០១២ | ៨,៧៥០ | ៩,៣៦០ | ១០,៨៦០ | ១៥,៧៥១ | ១៦,៥០១ | ១៦,៩៥១ |
| ២០១៣ | ៩,១៤០ | ១០,៣៦០ | ១៣,៣៦០ | ១៦,៥៣៨ | ១៨,១៥១ | ១៩,១៥៤ |
| ២០១៤ | ៩,៥៣០ | ១១,៣៦០ | ១៥,៨៦០ | ១៧,៣៦៥ | ១៩,៩៦៦ | ២១,៦៤៤ |
| ២៩១៥ | ៩,៩២០ | ១២,៣៦០ | ១៨,៣៦០ | ១៨,២៣៣ | ២១,៩៦២ | ២៤,៤៥៨ |
| ២០១៦ | ១០,៣១០ | ១៣,៣៦០ | ២០,៨៦០ | ១៩,១៤៥ | ២៤,១៥៩ | ២៧,៦៨៣ |
| ២០១៧ | ១០,៧០០ | ១៤,៣៦០ | ២៣,៣៦០ | ២០,១០២ | ២៦,៥៧៥ | ៣១,២៣១ |
| ២០១៨ | ១១,០៩០ | ១៥,៣៦០ | ២៥,៨៦០ | ២១,១០៧ | ២៩,២៣២ | ៣៥,២៩១ |
| ២០១៩ | ១១,៤៨០ | ១៦,៣៦០ | ២៨,៣៦០ | ២២,១៦៣ | ៣២,១៥៥ | ៣៩,៨៧៩ |

*(តួលេខ ពណ៌ក្រហម តំណាងអោយការប៉ាន់ប្រមាណលើចំនួនអ្នកទោសសរុប ដែលនឹងអាចមានចំនួនលើសពីលទ្ធភាពដែលផ្ទុកអ្នកទោសបាននៅក្នុងពន្ធនាគារ ទោះបីជាក្នុងករណីដែលអគ្គនាយកដ្ឋានពន្ធនាគារបាន ថែមកន្លែងសម្រាប់អ្នកទោសដល់ទៅ ២,៥០០ កន្លែងក្នុងមួយឆ្នាំក៏ដោយ)។*

តារាងបង្ហាញពីភាពប្រសើរឡើងនៃផ្នែកខ្លះ តាំងពីឆ្នាំ២០១០មក ប៉ុន្តែនៅមានហេតុផលចម្បងសម្រាប់ជាកង្វល់នៅឡើយ។

ជាឧទាហរណ៍ អង្គការលីកាដូ បានរាយការណ៍ក្នុងឆ្នាំ២០១០ថា ការបន្តនូវកំណើនអ្នកទោសដូចកម្រិតនាពេលបច្ចុប្បន្ននេះ អាចនាំកម្ពុជាអោយទៅជាប្រទេសដែលប្រព័ន្ធ

ពន្ធនាគារមានភាពចង្អៀតណែនខ្លាំងជាងគេបំផុតក្នុងពិភពលោកនៅឆ្នាំ២០១៨[១៩]។ ដោយសារតែអត្រាកំណើនមានការថយចុះបន្តិច ក្នុងឆ្នាំ២០១០ ដូច្នេះកាលបរិច្ឆេទត្រូវបានរុញទៅដល់ឆ្នាំ២០១៩[២០]។

ទោះបីជាយ៉ាងណាក៏ដោយ ក៏វានៅតែជាការពិតដែលថា បើសិនជាចំនួនអ្នកទោសសរុបរក្សាបាននូវអត្រាកំណើនប្រចាំឆ្នាំ ១០% ហើយប្រទេសកម្ពុជាអាចនឹងមានលទ្ធភាពបន្ថែមកន្លែងចំនួន២,៥០០កន្លែង ក្នុងពន្ធនាគារក្នុងមួយឆ្នាំក៏ដោយ ក៏នៅតែមិនអាចតាមអោយទាន់ល្បឿននៃចំនួនអ្នកទោសសរុបឡើយ។ និងសូម្បីតែការសន្មត់តាមទស្សនៈបែបអភិរក្ស (ការបន្ថែមកន្លែងថ្មីចំនួន៣៩០កន្លែង ក្នុងមួយឆ្នាំ និងអត្រាកំណើនអ្នកទោស ៥% ក្នុងរយៈពេលនោះ) ប្រព័ន្ធពន្ធនាគាររបស់ប្រទេសកម្ពុជាក៏នៅតែស្ថិតនៅក្នុងកម្រិត ១៩៣% នៃលទ្ធភាពដែលផ្ទុកអ្នកទោសនៅឆ្នាំ២០១៩។ លទ្ធផលដែលគណនាឃើញនេះ គួរឲ្យបារម្ភណ៍ជាងលទ្ធផលនៃការប៉ាន់ប្រមាណប្រហាក់ប្រហែលគ្នានេះកាលពីឆ្នាំមុន។

ហើយតួលេខខាងលើមិនទាន់បានគិតពិចារណាដល់តួលេខដែលមានភាពមន្ទិលសង្ស័យ នៃលទ្ធភាពដែលផ្ទុកអ្នកទោសបាន ដែលកំពុងតែប្រើប្រាស់នៅតាមពន្ធនាគារជាច្រើនរបស់ប្រទេសកម្ពុជានៅឡើយ។ ការគណនាដ៏ត្រឹមត្រូវលើលទ្ធភាពដែលផ្ទុកអ្នកទោសបាននឹងឆ្លុះបញ្ចាំងពីការពិតដ៏គួរឲ្យបារម្ភណ៍ជាងមុន។

ទីបំផុតមានហេតុផលដើម្បីជឿជាក់ថា កំណើនខ្លាំងនៃចំនួនអ្នកទោសនឹងបន្តមានយ៉ាងតិចណាស់ ក៏រហូតដល់ពេលដែលប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌត្រូវបានវាយតម្លៃឡើងវិញ លើការពឹងផ្អែកហួសហេតុចំពោះការឃុំឃាំងក្នុងពន្ធនាគារ។

អត្រាឃុំឃាំងថ្នាក់ជាតិរបស់ប្រទេសកម្ពុជាបច្ចុប្បន្ននេះ ស្ថិតនៅកម្រិត ៩៨.១នាក់ ក្នុងចំណោមប្រជាពលរដ្ឋ ១០,០០០នាក់ (ដប់ម៉ឺននាក់)។ ទោះបីជាអត្រានេះបានកើនឡើងជាលំដាប់ចាប់តាំងពីឆ្នាំ២០០៦ មកក៏ដោយ ក៏វានៅតែរក្សាបាននូវកម្រិតទាបដដែល បើគិតទៅតាមកម្រិតពិភពលោក។ យោងតាមការសិក្សាមួយ អត្រាឃុំឃាំងក្នុងកម្រិត៩៨.១ របស់ប្រទេសកម្ពុជានឹងចាត់ចូលទៅក្នុងចំណាត់ថ្នាក់ទី១៩០ នៃកម្រិតទូទាំងពិភពលោកចេញពីក្នុងចំនោមប្រព័ន្ធពន្ធនាគារចំនួន២១៦ ដែលត្រូវបានសិក្សា[២១]។ ប្រទេសស្ថិតនៅផ្នែកកណ្តាលនៃបញ្ជីឈ្មោះ មានរួមទាំងប្រទេសជិតខាងកម្ពុជាក្នុងតំបន់អាស៊ានគឺ វៀតណាម

[១៩] សូមអាន "ពិភពលោកទាំងមូល - អត្រាឃុំឃាំង" របស់មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការសិក្សាពីពន្ធនាគារ មាននៅគេហទំព័រ http://prisonstudies.org/info/worldbrief/wpb_stats.php?area=all&category=wb_occupancy

[២០] ជាការពិតណាស់ការដែលឈានទៅដល់កម្រិតនេះ អាស្រ័យលើអត្រាកំណើនអ្នកទោសនៃប្រទេសផ្សេងៗផងដែរ។

[២១] http://www.kcl.ac.uk/depsta/law/research/icps/worldbrief/wpb_stats.php?area=all&category=wb_poprate

ភូមា និងម៉ាឡេស៊ី ដែលមានអត្រាឃុំឃាំងកម្រិតប្រហែល ១២០នាក់ ទៅ ១៣០នាក់ ក្នុងចំនោមប្រជាពលរដ្ឋ ១០០,០០០នាក់ (ដប់ម៉ឺននាក់)។

## អត្រាឃុំឃាំងថ្នាក់ជាតិរបស់ប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ២០០៦

| ឆ្នាំ | ចំនួនប្រជាពលរដ្ឋសរុប[២២] | ចំនួនអ្នកទោសសរុប | ចំនួនអ្នកទោស ក្នុងចំនោមប្រជាពលរដ្ឋ ១០០,០០០ នាក់ |
|---|---|---|---|
| ២០០៦ | ១៤,០៩១,៨២៣ | ១០,៣៣៨ | ៧៣.៤ |
| ២០០៧ | ១៤,៣២៣,៨៤២ | ១០,៩០២ | ៧៦.១ |
| ២០០៨ | ១៤,៥៦២,០០៨ | ១១,៦៨៨ | ៨០.៣ |
| ២០០៩ | ១៤,៨០៥,៣៥៨ | ១៣,៣៤៥ | ៩០.១ |
| ២០១០ | ១៥,០៥២,២៤៣ | ១៤,០៤៣ | ៩៣.៤ |
| ២០១១ | ១៥,២៩៧,៩៦១ | ១៥,០០១ (ខែមេសា) | ៩៨.១ |

*(ទិន្នន័យចំនួនអ្នកទោសក្នុងពន្ធនាគារ តំណាងឲ្យតួលេខថ្នាក់ជាតិក្នុងខែធ្នូ ក្នុងឆ្នាំនីមួយៗ លើកលែងឆ្នាំ២០១១។ គួរកត់សំគាល់ថា ទិន្នន័យកាលពីឆ្នាំទៅ មាននៅក្នុងរបាយការណ៍លីកាដូ ឆ្នាំ២០១០ ដែលបានប្រើប្រាស់សំរាប់ការឃ្លាំមើលពន្ធនាគាររបស់អង្គការលីកាដូ តែប៉ុណ្ណោះ)*

[២២] ទិន្នន័យចំនួនប្រជាពលរដ្ឋសរុប តំណាងអោយចំនួនប៉ាន់ស្មានដែលដកស្រង់ចេញមកពី អាំងឌីកាទ័អភិវឌ្ឍពិភពលោក ធនាគារពិភពលោក [World Bank World Development Indicators] *មាននៅគេហទំព័រ* http://data.worldbank.org/indicator/SP.POP.TOTL ។ វាជាការគួរកត់សំគាល់ ដែលប្រភពគួរទុកចិត្តដទៃទៀត ប៉ាន់ប្រមាណតួលេខប្រជាពលរដ្ឋសរុបតិចជាងចំនួននេះជាខ្លាំងសម្រាប់ប្រទេសកម្ពុជា។ ឧទាហរណ៍ដូចជា CIA World Factbook ប៉ាន់ស្មានថា ចំនួនប្រជាពលរដ្ឋសរុបគិតត្រឹមខែកក្កដា ឆ្នាំ២០១១ គឺចំនួន ១៤,៧០១,៧១៧នាក់។ សូមអាន ប្រជាពលរដ្ឋ ប្រទេសកម្ពុជារបស់ CIA World Factbook *មាននៅគេហទំព័រ* https://www.cia.gov/library/publications/the-world-factbook/geos/cb.html។ ចំនួននេះនឹងដាក់អត្រាឃុំឃាំងរបស់ប្រទេសកម្ពុជានៅកម្រិត ១០២ ក្នុងចំណោមប្រជាពលរដ្ឋ ១០០,០០០នាក់។ ទន្ទឹមនឹងនេះដែរ វិទ្យាស្ថានជាតិស្ថិតិរបស់ប្រទេសកម្ពុជា ប៉ាន់ស្មានចំនួនប្រជាពលរដ្ឋសរុប ១៣,៣៩៥,៦៨២នាក់ ក្នុងឆ្នាំ ២០០៨។ កំណើនជាមធ្យម ១.៧% ដែលគិតទៅចំនួនប្រជាពលរដ្ឋសរុបសម្រាប់ឆ្នាំ២០០១ គឺ ១៤,០៩០,៥៩១នាក់។ ដូច្នេះវាត្រូវ នឹងអត្រាឃុំឃាំង ១០៦.៥នាក់ ក្នុងចំណោមប្រជាពលរដ្ឋ ១០០,000នាក់។ *សូមរកអាននៅគេហទំព័រ* http://www.nis.gov.kh/

## ២- កត្តារួមចំណែកដល់ភាពចង្អៀតណែនរបស់អ្នកទោស

របាយការណ៍ឆ្នាំ២០១០ របស់អង្គការលីកាដូ បានលើកមកបង្ហាញនូវកត្តាមួយចំនួនដែលរួមចំនែកដល់ការចង្អៀតណែនខ្លាំងនៅពន្ធនាគារ ដែលកត្តាទាំងអស់នេះគឺនៅតែជាបញ្ហាដដែល[២៣]។

តាំងពីឆ្នាំ២០១០មក របៀបនៃការដាក់ទណ្ឌកម្មលើអ្នកប្រព្រឹត្តិល្មើសច្បាប់ដោយប្រព័ន្ធយុត្តិធម៌ ព្រហ្មទណ្ឌមានការផ្លាស់ប្តូរតិចតួច។ ពន្ធនាគារនៅតែជាទម្រង់នៃការដាក់ទណ្ឌកម្មដែលគ្មានមធ្យោបាយផ្សេង ហើយការឃុំខ្លួនជាបណ្តោះអាសន្នរង់ចាំសវនាការនៅតែជាទម្រង់នៃការដាក់ទណ្ឌកម្ម ដែលត្រូវបានប្រើជាលក្ខណៈធម្មតា[២៤]។ អ្នកទោសខ្លះត្រូវបានឃុំខ្លួនជាបណ្តោះអាសន្នលើសនីតិវិធីដែលកំណត់ដោយច្បាប់ផងដែរ ខណៈដែលអ្នកទោសដទៃទៀតត្រូវបានជាប់ឃុំឃាំងហួសកាលកំនត់នៃរយៈពេលបំរើទោសរបស់ខ្លួន[២៥]។ អ្នកទោសដែលស្ថិតក្នុងដំណើរការនៃបណ្តឹងឧទ្ធរណ៍ ជួនកាលបានជាប់ឃុំឃាំងលើសពីទណ្ឌកម្មអតិបរិមាដែលតុលាការបានកំណត់ចំពោះបទល្មើសរបស់ខ្លួន សូម្បីតែពួកគេត្រូវបានសម្រេចអោយដោះលែងដោយសាលាដំបូងរាជធានីខេត្តក៏ដោយ[២៦]។

អង្គការលីកាដូ បានរកឃើញនូវបញ្ហាថ្មីដែលជាកង្វល់ក្នុងរយៈពេលមួយឆ្នាំកន្លងមកនេះ ដែលក្នុងចំណោមនេះមាន៣បញ្ហា ត្រូវបានលើកមកបង្ហាញខាងក្រោមៈ ទី១ៈការអនុវត្តការដាក់ពន្ធនាគារ ចំពោះអ្នកដែលមិនអាចបង់ ឬ មិនបង់ប្រាក់ពិន័យ ទី២ៈការបញ្ជូនអ្នកជាប់ឃុំឃាំងបណ្តោះអាសន្ន ទៅកាន់មជ្ឈមណ្ឌលព្យាបាលសារធាតុញៀនក្នុងមូលដ្ឋាន

---

[២៣] ចំពោះការពិភាក្សាជាបន្តលើប្រធានបទនេះ សូមអាន "គុកធំ-ចង្អៀតខ្លាំងៈ ភាពចង្អៀតណែនរបស់អ្នកទោស នៅកម្ពុជា និងក្តីស្រមៃនៃមណ្ឌលអប់រំកែប្រែទី៤" ពីទំព័រ ៩-១០។

[២៤] បញ្ហាដ៏ធំដែលកើតមានក្នុងបន្ទប់ឃុំឃាំងដែលគ្មាននរណានិយាយដល់ទាក់ទងនឹងភាពចង្អៀតណែន គឺអំពើពុករលួយនៅតាមដំណាក់កាលនានានៃដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។ ការស្រាវជ្រាវរបស់អង្គការលីកាដូ រកឃើញថា អំពើពុករលួយអាចដើរតួនាទីក្នុងការកំណត់ថា អ្នកណាដែលត្រូវចាប់ខ្លួន អ្នកណាដែលត្រូវផ្តន្ទាទោសអោយជាប់ពន្ធនាគារ អ្នកណាដែលត្រូវដាក់អោយជាប់ឃុំឃាំងជាបណ្តោះអាសន្ន រឿងក្តីរបស់អ្នកណា ដែលត្រូវដាក់អោយបើកសវនាការទាន់ពេលវេលា និងសូម្បីតែចំពោះអ្នកណាដែលមានឱកាសទទួលបានការដោះលែងមុនកាលកំណត់។ ឧទាហរណ៍មួយនៃចំណុចចុងក្រោយគឺការអនុវត្តការសុំលើកលែងទោស និងការបន្ធូរបន្ថយទោសដែលអាជ្ញាធរពន្ធនាគារស្នើរសុំឡើងក្នុងនាមអ្នកទោស ក្នុងអំឡុងបុណ្យជាតិសំខាន់ៗរបស់ប្រទេសកម្ពុជា។ អ្នកទោសបានប្រាប់អង្គការលីកាដូថា តម្លៃសម្រាប់ការស្នើរសុំក្នុងអំឡុងពេលបុណ្យចូលឆ្នាំខ្មែរ ឆ្នាំ២០១១ គឺពី២០០ដុល្លាសហរដ្ឋអាមេរិកទៅ ១,៣០០ដុល្លាសហរដ្ឋអាមេរិក អាស្រ័យទៅតាមពន្ធនាគារ និងថិរវេលានៃការបម្រើទោស។ តម្លៃនេះគឺគ្រាន់តែសម្រាប់ការស្នើសុំប៉ុណ្ណោះ ការទទួលបាន ឬ មិនទទួលបានជោគជ័យគឺមិនធានា នោះទេ។

[២៥] បញ្ហាខាងក្រោយនេះ ហាក់ដូចជាដោយសារតែភាពខ្សោយខាងការទុកដាក់ទិន្នន័យ និងឯកសាររួមផ្សំគ្នាជាមួយនឹងអំពើពុករលួយ។ សាលក្រមរបស់តុលាការកំរនឹងប្រគល់អោយទាន់ពេលវេលាដល់ពន្ធនាគារណាស់ ហើយមន្ត្រីពន្ធនាគារខ្លះអាចត្រូវការនូវ "ការជំរុញលើកទឹកចិត្ត" បន្ថែមទៀតដើម្បីរកបានសាលក្រមរបស់តុលាការ នៅពេលដែលមានអ្នកទោសត្រូវដល់ពេលដោះលែង។

[២៦] មាត្រា ៣៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ដែលនៅទីនោះពួកគេត្រូវបានឃុំឃាំងក្រោមផ្លាកថា "ព្យាបាល" និងទី៣៖ការប្រើទណ្ឌកម្មដាក់ពន្ធនាគារដែលមិនសមាមាត្រទៅនឹងបទល្មើស។

## ជាប់ទោសដោយសារភាពក្រីក្រ: បន្ថែមពេលជាប់ពន្ធនាគារ បើមិនអាចបង់ប្រាក់ពិន័យ

មានអ្នកទោសដែលមិនដឹងចំនួនពិតប្រាកដ ត្រូវបានជាប់ឃុំឃាំងក្នុងពន្ធនាគារលើសពេលកំណត់នៃរយៈពេលបំរើទោសរបស់អ្នកទាំងអស់នោះ ពីព្រោះតែអ្នកទាំងនោះគ្មានលទ្ធភាពបង់ប្រាក់ពិន័យ។ ច្បាប់កម្ពុជា ព្រះរាជអាជ្ញាមានអំណាចដាក់ការបង្ខំដែលមានរយៈពេល បន្ថែមក្នុងពន្ធនាគាររហូតដល់២ឆ្នាំ ចំពោះករណីមិនបង់ប្រាក់ពិន័យនេះ[២៧]។

គោលគំនិតនៃបទបញ្ញត្តិនេះគឺថា ការគំរាមដាក់ពន្ធនាគារនឹងជួយដល់ព្រះរាជអាជ្ញាអោយប្រមូលបានប្រាក់ពិន័យពីភាគីដែលស្ទាក់ស្ទើរក្នុងការបង់។ ខណៈដែលការគំរាមកំហែងដាក់ពន្ធនាគារបែបនេះអាចបានផលនៅក្នុងករណីមួយចំនួនដែលមិនមានកំណត់ពីការដាក់ទោសជាប់ពន្ធនាគារពីដំបូងមកនោះ តែមានអត្ថន័យតិចតួចណាស់ដែលប្រើបញ្ញត្តិនេះចំពោះអ្នកដែលជាប់ឃុំឃាំងរួចទៅហើយ។

ទីមួយ៖ ការដាក់ពន្ធនាគារជំនួសការបង់ប្រាក់ពិន័យ ដែលបានបង្ខំត្រូវបានកំណត់ដោយមិនបានពិចារណាពីលទ្ធភាពនៃការបង់ប្រាក់ពិន័យ ដែលការកំណត់នេះសម្រាប់អ្នកក្រីក្រគឺជាបន្ទុកដ៏ធ្ងន់ធ្ងរមួយ។ ការអនុវត្តការរក្សា (អ្នកទោសក្រីក្រដែលជាអ្នកមិនអាចមានលទ្ធភាពបង់ប្រាក់ពិន័យបាន) ដាក់ក្នុងពន្ធនាគារមិនបានជួយរដ្ឋក្នុងការប្រមូលថវិកាទេ[២៨]។ វាគ្រាន់តែធ្វើអោយរដ្ឋខាតបង់ថវិកាថែមទៀត ដោយការចំណាយលើការឃុំឃាំង[២៩]។

ទីពីរ៖ ទោះបីជាក្រមនីតិវិធីព្រហ្មទណ្ឌកំណត់ការបង្ខំចំពោះអ្នកដែលមិនបង់ប្រាក់ពិន័យ*ត្រូវអនុវត្ត*[៣០]ដោយស្វ័យប្រវត្តិក៏ដោយ ក៏បានចែងយ៉ាងច្បាស់ផងដែរថា ព្រះរាជអាជ្ញាគួរតែចាត់នូវជំហានជាក់លាក់មួយចំនួន មុនពេលមានការចេញដីកាឃុំខ្លួន[៣១]។ ដូច្នេះការដាក់ពន្ធនាគារ មិនគួរត្រូវបានអនុវត្តជា*ស្វ័យប្រវត្តិ* នោះទេក្នុងការអនុវត្តជាក់ស្ដែង។

---

[២៧] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៥២៤ និងមាត្រា ៥៣០ ដែលមាត្រា៥៣០ ចែងថា ថិរវេលានៃការបង្ខំដល់រូបកាយ អាចត្រូវកំណត់ចាប់ពី រយៈពេលបន្ថែម ១០ថ្ងៃ ចំពោះប្រាក់ពិន័យចំនួន ២៥០,០០០រៀល (US$៦២.៥០) និងរយៈពេល ក្រោម ២ឆ្នាំ ចំពោះប្រាក់ពិន័យលើសពីចំនួន ៥០លានរៀល (US$១២,៥០០) ។

[២៨] វាក៏មិនមែនជាមធ្យោបាយដ៏មានប្រសិទ្ធិភាពបំផុតដែលចាំបាច់សម្រាប់ប្រមូលប្រាក់ពិន័យពីចុងចោទ ដែលជាអ្នកមានទ្រព្យសម្បត្តិនោះដែរ។ រាជរដ្ឋាភិបាលមានជម្រើសផ្សេងៗក្នុងលទ្ធភាពរបស់ខ្លួន ដូចជាការរឹបអូសទ្រព្យសម្បត្តិ និងកាត់យកប្រាក់ខែ (ដូចជាក្នុងករណី លោកស្រី មូ៉ សុខហួរ អ្នកតំណាងរាស្ត្រ គណបក្សសម រង្ស៊ី ដែលប្រាក់ខែរបស់គាត់ត្រូវបានកាត់យកដើម្បីបង់ប្រាក់ពិន័យក្នុងករណីបរិហាកេរ្ដិ៍មួយ)។

[២៩] ទន្ទឹមនឹងនេះ អ្នកទោសដែលនៅខាងក្រៅអាចមានលទ្ធភាពច្រើនក្នុងការរកប្រាក់ដើម្បីបង់ប្រាក់ពិន័យ។ វាជាការគួរកត់សម្គាល់ផងដែរថា អ្នកដែលបានទទួលការបង្ខំរូបកាយរួចហើយនោះ នៅតែមិនរួចផុតពីបំណុលដដែល។ *សូមអាន* មាត្រា ៥៣២។

[៣០] *ដូចខាងលើ* មាត្រា៥២៤ ("ការបង្ខំដល់រូបកាយត្រូវអនុវត្តដោយពេញលក្ខណៈច្បាប់ ហើយមិនចាំបាច់ប្រកាសដោយតុលាការទេ។")

[៣១] *ដូចខាងលើ* មាត្រា៥២៥ ដល់ មាត្រា៥៣៣។

មានជំហានជាច្រើនដែលតម្រូវអោយចាត់ឡើងដើម្បីនឹងចេញដីកាឃុំខ្លួន ចំពោះជនដែលមិនបង់ប្រាក់ពិន័យ។ វាតម្រូវអោយព្រះរាជអាជ្ញាកំណត់រយៈពេលចុងក្រោយដើម្បីឲ្យទណ្ឌិតបង់ប្រាក់នោះ អោយដំណឹងអំពីរយៈពេលចុងក្រោយនោះដល់ទណ្ឌិតធ្វើកំណត់ហេតុស្តីពីការអោយដំណឹងនេះ កំណត់ហេតុត្រូវចុះហត្ថលេខាដោយទណ្ឌិត បន្ទាប់ពីការជូនដំណឹងត្រូវទុករយៈពេលយ៉ាងតិចណាស់១០ថ្ងៃដល់ទណ្ឌិតដើម្បីបង់ប្រាក់ ហើយជំហានចុងក្រោយគឺចេញ "ដីកាឃុំខ្លួនពិសេស" ប្រសិនបើទណ្ឌិតមិនបានបង់ប្រាក់នោះទេ[៣២]។ ទណ្ឌិតអាចតវ៉ាអំពីសេចក្តីសំរេចដីកាឃុំខ្លួនពិសេសនោះដែល ក្នុងករណីនេះទណ្ឌិតត្រូវបានគេនាំទៅចំពោះមុខតុលាការ[៣៣]។ ឬព្រះរាជអាជ្ញាអាចបង្អង់សេចក្តីសម្រេចនេះបានដោយ "មូលហេតុមនុស្សធម៌"[៣៤]។

ច្បាប់មិននិយាយច្បាស់លាស់ថានឹងមានរឿងអ្វីកើតឡើង បើព្រះរាជអាជ្ញាមិនបានចាត់នូវជំហានទាំងនេះ ប៉ុន្តែជាគោលកាណ៍ច្បាប់ច្បាស់លាស់ណាស់ថា ការបន្តការឃុំឃាំងអាចទៅជា គឺរឿងខុសច្បាប់ខាងបច្ចេកទេស។ បន្ទាប់ពីផុតរយៈពេលបំរើទោសអគ្គនាយកដ្ឋានពន្ធនាគារមិនមានបទបញ្ជាឃុំឃាំង ដែលមានប្រសិទ្ធភាពតទៅទៀតទេដើម្បីបន្តឃុំឃាំងទណ្ឌិត។

អ្នកទោសដែលត្រូវបានសម្ភាសន៍ដោយអង្គការលីកាដូបាននិយាយថា ក្នុងការអនុវត្តជាក់ស្តែង ព្រះរាជអាជ្ញាកម្រនឹងមានចំណាត់ការចំពោះជំហាននានាដែលបានតម្រូវ ដើម្បីនឹងចេញដីកាឃុំខ្លួនពិសេសនេះណាស់។ ដោយការមិនយកចិត្តទុកដាក់ក្នុងការចេញដីកាដោះលែងរបស់ព្រះរាជអាជ្ញានេះ ធ្វើឲ្យមន្ត្រីពន្ធនាគារយល់ថាត្រូវបន្តឃុំឃាំងអ្នកទោសតទៅទៀត ចំពោះការខកខានក្នុងការបង់ប្រាក់ពិន័យ។

នេះគឺជាបញ្ហាមួយ ដែលមិនត្រឹមតែបង្ហាញពីការមិនគោរពប្រព័ន្ធនីតិរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានដកហូតពីជនជាប់ចោទ នូវសិទ្ធិទទួលបាននូវការការពារដ៏សំខាន់ខាងនីតិវិធីត្រឹមត្រូវ ហើយប្រហែលជារឿងដែលគួរឲ្យព្រួយបារម្ភណ៍ជាខ្លាំង ពីព្រោះវាអាចនាំឲ្យមានការ "ជាប់ទោសដោយសារភាពក្រីក្រ" តាមរយៈការបន្តទោសរបស់ទណ្ឌិតនៅក្នុងពន្ធនាគារ ដោយមិនបានបង្ហាញឲ្យឃើញពីចំនួនពិតប្រាកដ។

---

[៣២] *ដូចខាងលើ* មាត្រា៥២៥ ដល់ មាត្រា៥២៦។

[៣៣] *ដូចខាងលើ* មាត្រា៥២៧។

[៣៤] *ដូចខាងលើ* មាត្រា៥២៦។ ច្បាប់មិននិយាយពីអ្វីដែលជាលក្ខខណ្ឌជាក់លាក់ដែលសមស្របនៃ "មូលហេតុមនុស្សធម៌" នោះទេ។ ទោះបីជាយ៉ាងណាក៏ដោយអង្គការលីកាដូ សូមផ្តល់អនុសាសន៍ដ៏មុតមាំថា ដើម្បីធ្វើអោយមានភាពធូរស្រាលដល់បញ្ហាចង្អៀតណែននៅពន្ធនាគារគួរគិតគូពិចារណាលើមូលហេតុមនុស្សធម៌ សមស្រប សម្រាប់អោយព្រះរាជអាជ្ញាមិនចេញបញ្ជាអោយបង្ខំ និងឃុំខ្លួន។

ករណីនាពេលថ្មីៗ បង្ហាញពីភាពមិនសមទំនង និងមិនចាំបាច់ទាល់តែសោះនៃប្រព័ន្ធនេះ ដែលបានរួមចំនែកដល់ភាពចង្អៀតណែនរបស់អ្នកទោស។

ក្នុងឆ្នាំ២០១០ អង្គការលីកាដូ បានជួបជាមួយអ្នកទោសដែលត្រូវបានកាត់សេចក្តីអោយជាប់ទោសពីបទល្មើសតូចតាចទាក់ទងនឹងគ្រឿងញៀន។ ក្នុងពេលនៃការចាប់ខ្លួនរបស់គាត់ គាត់មានប្រាក់ជាប់នឹងខ្លួនប្រហែលជា៥០០ដុល្លាសហរដ្ឋអាមេរិក ដែលជាក្រដាសប្រាក់ក្លែងក្លាយ។ តុលាការបានសំរេចកំណាត់អោយមានទោសជាប់ពន្ធនាគាររយៈពេល១៨ខែ ចំពោះបទល្មើសទាក់ទងនឹងគ្រឿងញៀន និងពិន័យជាប្រាក់ចំនួន៥០,០០០ដុល្លាសហរដ្ឋអាមេរិក ចំពោះការមានក្រដាសប្រាក់ក្លែងក្លាយ។

អ្នកទោស មិនអាចបង់ប្រាក់ពិន័យបាន ហើយបន្ទាប់ពីគាត់បានបំរើទោសជាប់ពន្ធនាគារទាក់ទងនឹងបទល្មើសគ្រឿងញៀនចប់សព្វគ្រប់ មន្ត្រីពន្ធនាគារបានប្រាប់គាត់ថាគាត់ត្រូវបំរើទោសបន្ថែមរយៈពេល២ឆ្នាំទៀត[៣៥] - ដែលមានរយៈពេលច្រើនជាងពីរដងនៃទោសពីដំបូង ដែលកំណត់ដោយតុលាការ។

អ្នកទោសបានជំរាបអ្នកស្រាវជ្រាវអង្គការលីកាដូថា ព្រះរាជអាជ្ញាដែលធ្វើការលើករណីរបស់គាត់មិនបានអនុវត្តតាមនីតិវិធីនៃការចេញដីកាឃុំខ្លួនពិសេស ដូចដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនោះទេ។ អង្គការលីកាដូ បានអន្តរាគមន៍ និងបានស្នើសុំអោយព្រះរាជអាជ្ញាបោះបង់ចោលសិទ្ធិរបស់គាត់ក្នុងការចេញបញ្ជាដាក់ទោសក្នុងពន្ធនាគារបន្ថែម។

បន្ទាប់ពីការពន្យាពេលយ៉ាងយូរមក ទីបំផុតមន្ត្រីពន្ធនាគារបានអោយដំណឹងជាលាយល័ក្ខអក្សរដល់អ្នកទោសអំពីប្រាក់ពិន័យ និងរយៈពេលផុតកំណត់សម្រាប់ការបង់ប្រាក់ពិន័យ។ អ្នកទោសត្រូវបានគេបង្ខំអោយចុះហត្ថលេខាលើឯកសារកំណត់ហេតុ។ ក្នុងពេលរង់ចាំការផុតកំណត់នៃរយៈពេលកំណត់អោយបង់ប្រាក់ពិន័យ ១០ថ្ងៃនោះ គាត់មិនត្រូវបានគេដោះលែងអោយចេញពីពន្ធនាគារទេ ហើយព្រះរាជអាជ្ញាក៏មិនបានចេញដីកាឃុំខ្លួនពិសេសនោះដែរ។ ទីបំផុតគាត់បានទទួលទោសជាប់ពន្ធនាគារបន្ថែមរយៈពេល ២ឆ្នាំ ដែលនាំអោយទោសជាប់ពន្ធនាគារសរុបរបស់គាត់មានរយៈពេល ៣ឆ្នាំ កន្លះ។

[៣៥] ប្រាក់ពិន័យដែលមិនបានបង់ចំនួន៥០លានរៀល (១២,៥០០ដុល្លាសហរដ្ឋអាមេរិក) ឬច្រើនជាងនេះ នាំទៅដល់ការបន្ថែមទោសជាប់ពន្ធនាគាររយៈពេល ២ឆ្នាំ ទៀត។ ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា៥៣០។

តើអ្វីទៅជាគោលបំណងពិតប្រាកដរបស់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ចំពោះការដាក់បន្ថែមរយៈពេលជាប់ពន្ធនាគារដល់អ្នកក្រីក្រ ដែលមិនអាចមានលទ្ធភាពបង់ប្រាក់ពិន័យរបស់ពួកគេនោះ? រដ្ឋនឹងបានប្រសើរឡើងលើគ្រប់ទិដ្ឋភាព បើសិនជាអ្នកទោសគ្រាន់តែត្រូវបានទទួលការដោះលែងទាន់ពេលវេលា ដោយមិនគិតពីការដែលថា តើប្រាក់ពិន័យត្រូវបានបង់ឬ មិនបង់នោះ។ ការដោះលែងអ្នកទោសម្នាក់មានន័យថាមានការថយចុះចំនួនអ្នកទោសម្នាក់សម្រាប់អោយរដ្ឋចិញ្ចឹមនិងផ្តល់កន្លែងស្នាក់នៅ។ ក៏មានន័យផងដែរថា អ្នកទោសអាចវិលត្រលប់ទៅប្រកបការងារវិញ និងខិតខំដើម្បីអោយខ្លួនបានបង់ប្រាក់ពិន័យរួច។

*ជាជម្រើសផ្សេង រដ្ឋគួរតែអនុវត្តប្រព័ន្ធអនុវត្តទោសដំណាលគ្នា ចំពោះការដាក់ទោសជំនួសការបង់ប្រាក់ពិន័យ។* ក្រោមប្រព័ន្ធនេះជនជាប់ចោទដែលត្រូវបានសំរេចអោយជាប់ពន្ធនាគារអាចត្រូវបានតម្រូវអោយបង់ប្រាក់ពិន័យភ្លាមៗ ក្នុងពេលចូលខ្លួនទៅក្នុងពន្ធនាគារ។ បើសិនជាអ្នកទាំងនោះមិនអាចបង់ប្រាក់ពិន័យបាន អាចដាក់បន្ថែមរយៈពេលជាប់ពន្ធនាគារ។ ទោះបីជាយ៉ាងណាក៏ដោយ ការដាក់បន្ថែមរយៈពេលជាប់ពន្ធនាគារនេះត្រូវតែអនុវត្តទៅទន្ទឹមគ្នានឹងទោសជាប់ពន្ធនាគារដំបូង។ ដូច្នេះ បុគ្គលដែលមានទោសជាប់ពន្ធនាគាររយៈពេល១៨ខែ និងមិនអាចបង់ប្រាក់ពិន័យចំនួន ៥០,០០០ដុល្លាសហរដ្ឋអាមេរិក បាននឹងបំរើទោសសរុប*ចំនួន ២ឆ្នាំ* ជាជាងការបំរើទោស ១៨ខែ បូករយៈពេលបន្ថែម ២ឆ្នាំទៀត។

## ជម្រើសផ្សេងក្រៅពីការឃុំឃាំងក្នុងពន្ធនាគារៈ មិនចំចំណុចនៃបញ្ហា



*កន្លែងគេងរបស់អ្នកទោសបុរសមជ្ឈមណ្ឌលព្យាបាលសារធាតុញៀន ភ្នំបាក់*

អង្គការលីកាដូ បានផ្តល់អនុសាសន៍ក្នុងរបាយការណ៍ពីមុនថា ការប្រើជម្រើសផ្សេងអោយបានច្រើន ក្រៅពីការដាក់ពន្ធនាគារ មានដូចជា សេវាតាមសហគមន៍ ការបង់ប្រាក់ធានានៅក្រៅឃុំ និងការព្យួរទោស អាចនឹងជួយកាត់បន្ថយចំនួនអ្នកទោសនៅតាមពន្ធនាគារ។

មានការរីកចំរើនតិចតួចបំផុតលើការអនុវត្តនៃជម្រើសក្រៅពីការដាក់ពន្ធនាគារនេះ ដែលបានបង្ហាញតាមរយៈកំណើនជាអចិន្ត្រៃយ៍នៃចំនួនអ្នកទោស។ ការផ្តន្ទាទោសមិនដាក់ពន្ធនាគារ នៅតែមិនយកមកប្រើការធានានៅក្រៅឃុំបានប្រើប្រាស់មិនដល់កំរិត (អ្នកជាប់ឃុំឃាំងជាបណ្តោះអាសន្ន រងចាំសវនាការមានចំនួនមួយភាគបីនៃចំនួនអ្នកទោសសរុបទាំងអស់) ហើយប្រព័ន្ធដោះលែងដោយមានលក្ខខណ្ឌដែលអនុញ្ញាតិដោយក្រមនីតិវិធីព្រហ្មទណ្ឌ[៣៦] មិនត្រូវបានយកមកអនុវត្តទេ[៣៧]។

## *ការឃុំឃាំងដោយរូបភាពផ្សេង*



*រូបនៅលើជញ្ជាំងមជ្ឈមណ្ឌលព្យាបាលសារធាតុញៀន ភ្នំបាក់ បង្ហាញអ្នកជាប់ឃុំឃាំងដែលមានអាយុប្រហែលពី១៥ឆ្នាំឡើងទៅ*

ករណីលើកលែងមួយក្រៅពីអ្វីដែលបានរៀបរាប់ខាងលើ គឺការសាកល្បងមួយដែលកំពុងតែប្រព្រឹត្តិទៅនាពេលថ្មីៗនេះ គឺនៅក្នុងខេត្តបន្ទាយមានជ័យ។ ប៉ុន្តែ ប្រហែលមិនមែនជាគំរូមួយសម្រាប់អនុវត្តតាម នៅទូទាំងប្រទេសនោះទេ។ ពាក់ព័ន្ធនឹងការបញ្ជូនអ្នកជាប់ឃុំឃាំងបណ្តោះអាសន្ន រងចាំសវនាការ ទៅមជ្ឈមណ្ឌលព្យាបាលសារធាតុញៀនក្នុងមូលដ្ឋានជាទីកន្លែងដែលអ្នកទាំងនោះត្រូវបានដាក់ឃុំឃាំងក្រោមផ្លាក "ព្យាបាល"។ ជាធម្មតាមជ្ឈមណ្ឌលព្យាបាលសារធាតុញៀនមិនមានមុខងារជាមណ្ឌលឃុំឃាំងបណ្តោះអាសន្នទេ។

ប៉ុន្តែព្រះរាជអាជ្ញា និងចៅក្រមក្នុងខេត្តបន្ទាយមានជ័យដោះស្រាយបញ្ហានោះដោយយកបែបបទផ្លូវច្បាប់

[៣៦] *ដូចខាងលើ* មាត្រា៥១២ ដល់មាត្រា ៥២២។

[៣៧] នេះប្រហែលជាដោយសារតែក្រសួងយុត្តិធម៌មិនបានចេញនូវប្រកាស ដែលច្បាប់បានតម្រូវ។ "សូមអាន មាត្រា ៥២២ ("បែបបទនៃការឃ្លាំមើលតាមដានការត្រួតពិនិត្យ និងការបញ្ចូលទៅក្នុងសង្គមវិញនៃទណ្ឌិតដែលដោះលែងដោយមានលក្ខខណ្ឌត្រូវកំណត់ដោយប្រកាសរបស់ក្រសួងយុត្តិធម៌។ ប្រកាសនេះអាចប្រគល់អោយស្ថាប័នសាធារណៈ ឬឯកជននូវការយកចិត្តទុកដាក់ធានារ៉ាប់រងលើការបញ្ចូលទណ្ឌិតទៅក្នុងសង្គមវិញ។")

ខ្លះមកអនុវត្តៈ ក្នុងខែមេសា ឆ្នាំ២០១១ អ្នកជាប់ឃុំឃាំងបណ្តោះអាសន្នរង់ចាំសវនាការសរុបចំនួន ៣៨នាក់ ដែលអ្នកទាំងអស់នោះត្រូវបានចាប់ខ្លួនពីបទប្រើប្រាស់គ្រឿងញៀន ត្រូវបានដោះលែងជាលើកដំបូងតាមរយៈការធានានៅក្រៅឃុំ។ លក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌនានាសម្រាប់ការដោះលែងរបស់អ្នកទាំងអស់នោះ គឺត្រូវបំពេញកម្មវិធីព្យាបាលសារធាតុញៀន។ ដូច្នេះបន្ទាប់ពីការដោះលែងអ្នកទាំងអស់នេះ ត្រូវបានគេនាំយកដោយផ្ទាល់ទៅកាន់មជ្ឈមណ្ឌលព្យាបាលសារធាតុញៀនជីវិតថ្មី ភ្នំបាក់។ មជ្ឈមណ្ឌលនេះប្រតិបត្តិការរួមគ្នាដោយអាជ្ញាធរខេត្ត និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក.ស.អ.យ)។

ការសំរេចលើការធានាអោយនៅក្រៅឃុំ ជាបច្ចេកទេសហាក់ដូចជាស្របច្បាប់តាមច្បាប់បច្ចុប្បន្ន។ មាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ អនុញ្ញាតិអោយ ចៅក្រមចេញដីកាដែលមានលក្ខខណ្ឌមួយចំនួនដល់ជនជាប់ឃុំបណ្តោះអាសន្នរង់ចាំសវនាការដែលបានដោះលែងនៅក្រៅឃុំ។ លក្ខខណ្ឌទាំងនោះមានរួមទាំងកាតព្វកិច្ចមួយគឺ "ត្រូវប្រគល់ ខ្លួនអោយពេទ្យពិនិត្យ និង/ឬ ព្យាបាល។"

ក៏ប៉ុន្តែកម្មវិធីព្យាបាលសមស្របនេះ មិនមែនជាការចាំបាច់មួយនៃដំណោះស្រាយសមរម្យទេ។ ការពិតអំពីមជ្ឈមណ្ឌលភ្នំបាក់បង្ហាញថា គ្រោងការនៃការដោះលែងដោយមានលក្ខខណ្ឌ គឺគ្មានអ្វីជាជាងគ្រោងការមិនប្រក្រតីដែលរៀបចំឡើង ដើម្បីមិនបង្ហាញការពិតពីវិបត្តចង្អៀតណែនដ៏ធ្ងន់ធ្ងររបស់ពន្ធនាគារខេត្តបន្ទាយមានជ័យនោះទេ។ វិបត្តិ ដែលបង្កមួយផ្នែកដោយប្រតិបត្តិការមិនប្រក្រតីរបស់រាជរដ្ឋាភិបាល លើការបង្ក្រាបអ្នកប្រើប្រាស់គ្រឿងញៀន[៣៨]។

## *'កម្មវិធីមានដែនកំណត់ និងគំនិតទស្សនៈពេញដោយចម្ងល់'*

អ្នកស្រាវជ្រាវអង្គការលីកាដូ ដែលបានធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលភ្នំបាក់ ក្នុងខែឧសភា ឆ្នាំ២០១០ រកឃើញថា មណ្ឌលនេះផ្តល់អោយមាននូវកម្មវិធីដ៏មានកំរិត និងអនុវត្តនូវគំនិត ទស្សនៈនៃការស្តានីតិសម្បទាដែលពេញទៅដោយមន្ទិលសង្ស័យ។ កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចជា វិជ្ជាខាងផ្នែកអេឡិចត្រូនិច កសិកម្ម ជាងផ្សារដែក និងកាត់សក់ មិនបានបង្ហាញរូបភាពជាសកម្មទេ។ គ្រឿងបរិក្ខារនៅក្នុងបន្ទប់រៀនខាងផ្នែកអេឡិចត្រូនិច គ្រប

---

[៣៨] កាសែតភ្នំពេញប៉ុស្តិ៍ បានរាយការណ៍ថា មានមនុស្សចំនួន៥១៧នាក់ ត្រូវបានចាប់ខ្លួនពីបទពាក់ព័ន្ធនឹងគ្រឿងញៀន នៅក្នុងរាជធានីភ្នំពេញរវាងថ្ងៃទី០១ ខែមករា និងខែឧសភា ឆ្នាំ២០១១។ ឆាយ ចាន់ឌីណា និង ប៊ុត រស្មីគង្គា "ករណីគ្រឿងញៀនដ៏ធំត្រូវបានលាតត្រដាង" កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១១។

ដណ្តប់ពេញទៅដោយធូលី ហើយបន្ទប់រៀនខាងជាងផ្សារដែកគ្មានសម្ភារៈអ្វីទាំងអស់។ លំហាត់ប្រាណ និងកីឡា ហាក់បីដូចគឺជាសកម្មភាពជាចម្បងដូចដែលបុគ្គលិករបស់មជ្ឈមណ្ឌលបានប្រាប់យើងថា អ្នករស់នៅក្នុងមជ្ឈមណ្ឌលត្រូវ ″បញ្ចេញញើសដើម្បីអោយជាតិញៀនចេញពីក្នុងខ្លួនរបស់គេ″។

ក.ស.អ.យ មិនអាចចាត់ចែងសូម្បីតែអោយមានបុគ្គលិកសម្រាប់បម្រើការងារនៅមណ្ឌល។ កាលពីមុនមណ្ឌលភ្នំបាក់ ធ្លាប់មានបុគ្គលិកបំរើការចំនួន ៧នាក់ ប៉ុន្តែឥឡូវនេះមានបុគ្គលិកតែបីនាក់ទេគឺ ប្រធាន អនុប្រធាន និងប្រធានកម្មវិធី។ មានបុគ្គលិកខាងសន្តិសុខចំនួន ៨នាក់ ផងដែរ ដែលផ្តល់អោយដោយស្នងការនគរបាលខេត្ត ក្នុងនោះមានប្រធានសន្តិសុខម្នាក់ បំពេញការងារជាវេជ្ជបណ្ឌិតរបស់មណ្ឌលផងដែរ។

ពួថាមជ្ឈមណ្ឌលនេះ ដូចគ្នានឹងមជ្ឈមណ្ឌលព្យាបាលសារធាតុញៀនទាំងអស់របស់ប្រទេសកម្ពុជា ដែលមានសណ្ឋានត្រឹមតែជាកន្លែងសម្រាប់អ្នកប្រើប្រាស់គ្រឿងញៀនដែលដំណើរការដូចគ្នានឹងប្រព័ន្ធពន្ធនាគារ។ ហើយមានវិធីខ្លះ មជ្ឈមណ្ឌលព្យាបាលសារធាតុញៀនរបស់ប្រទេសកម្ពុជា អាចនឹងពិបាកជាងពន្ធនាគារទៅទៀត។ អ្នកជាប់ឃុំឃាំងក្នុងមជ្ឈមណ្ឌល មិនត្រូវបានផ្តន្ទាទោសពីបទល្មើស ហើយក៏មិនដឹងច្បាស់ពីកាលបរិច្ឆេទនៃការដោះលែង។ ជាញឹកញាប់ ពួកគេត្រូវបានប្រមូលចេញពីតាមដងផ្លូវ និងនាំយកទៅដាក់ក្នុងមណ្ឌលទាំងនោះតែម្តង។ មិនមានការគោរពតាមនីតិវិធីត្រឹមត្រូវនៃច្បាប់ និងមិនមានផ្តល់ឱកាសដើម្បីបង្ហាញភស្តុតាងពីភាពគ្មានកំហុស។

*ពួថាមជ្ឈមណ្ឌលនេះ ដូចគ្នានឹងមជ្ឈមណ្ឌលព្យាបាលសារធាតុញៀនទាំងអស់ របស់ប្រទេសកម្ពុជាដែរមានសណ្ឋានត្រឹមតែជាកន្លែងសម្រាប់អ្នកប្រើប្រាស់គ្រឿងញៀនដែលដំណើរការដូចគ្នានឹងប្រព័ន្ធពន្ធនាគារ។*

ការសង្កេតទាំងអស់នេះគឺគ្រាន់តែជាចំណែកតូចមួយនៃចំណែកដ៏ធំនៃបញ្ហា។ បញ្ហាពាក់ព័ន្ធមជ្ឈមណ្ឌលព្យាបាលគ្រឿងញៀនរបស់រដ្ឋ (មានខ្លះជាអំពើទារុណកម្ម ពលកម្មដោយបង្ខំ និងអវត្តមានទាំងស្រុងនៃកម្មវិធីព្យាបាលសារធាតុញៀនដែលទទួលស្គាល់ត្រឹមត្រូវតាមច្បាប់) ហើយដែលបានសរសេរចងក្រងយ៉ាងពិស្តារនៅក្នុងរបាយការណ៍ ″ស្បែក

ជាប់ខ្សែភ្លើង″ របស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស ដែលបានចេញផ្សាយក្នុងខែមករា ឆ្នាំ ២០១០[៣៩]។

ការផ្លាស់ប្តូរពីពន្ធនាគារទៅមជ្ឈមណ្ឌលនាពេលថ្មីនេះ គឺជាបញ្ហាផងដែរ ពីព្រោះបានដាក់អ្នកដែលត្រូវគេបញ្ជូនចំនួន៣៨នាក់ អោយនៅក្នុងដែននីត្យានុកូលមួយដែលមិនធ្លាប់មានពីមុនមក។ ទោះបីជាវគ្គព្យាបាលសារធាតុញៀនធម្មតាមានរយៈពេលប្រហែលជា ៦ខែ ដែលសន្មត់ថា "បានជោគជ័យពេញលេញ″ ដូចដែលបានបញ្ជាក់ដោយបុគ្គលិកមជ្ឈមណ្ឌលក៏ដោយ ក៏មិនមានការធានាថា អ្នកដែលត្រូវគេបញ្ជូនចំនួន៣៨នាក់នោះ នឹងត្រូវបានអនុញ្ញាតិអោយចាកចេញពីមជ្ឈមណ្ឌលក្នុងរយៈពេល៦ខែដែរ។ ហើយក៏មិនមានការធានាណាមួយថា បទព្រហ្មទណ្ឌដែលបានចោទប្រកាន់អ្នកទាំងអស់នោះ នឹងត្រូវបានលើកលែងចោទប្រកាន់ជាផ្លូវការ។ ប្រសិនបើបទចោទមិនត្រូវបានលើកលែងទេ នោះអាជ្ញាយុកាលនៃបទល្មើសនឹងនៅតែបន្ត ( ចិរវេលា ១៥ឆ្នាំ ចំពោះបទឧក្រិដ្ឋ និង ៥ឆ្នាំ ចំពោះបទមជ្ឈឹម)[៤០]។

ខណៈនេះដែរ ចៅក្រមបានប្រាប់អង្គការលីកាដូថា បើសិនជាអ្នកជាប់ពន្ធនាគារហើយត្រូវបានបញ្ជូនទៅភ្នំបាក់ ដើម្បីព្យាបាលពេលវេលានោះនឹងមិនត្រូវបានរាប់បញ្ចូលជាមួយចិរវេលានៃទោសរបស់អ្នកទាំងនោះទេ។

## *ភាពចង្អៀតណែន និងទំនាក់ទំនងជាមួយនឹងបទល្មើសគ្រឿងញៀន*

នេះហើយដែលជាបញ្ហាធំបំផុតនៃភាពចង្អៀតណែនរបស់អ្នកទោស។

អ្នកទោសនៅពន្ធនាគារខេត្តបន្ទាយមានជ័យ មានចំនួនច្រើនលើសលុបនាពេលថ្មីៗនេះ ដែលកើនឡើងពី៨១៦នាក់ ក្នុងខែឧសភា ឆ្នាំ២០១០ ទៅដល់១,០៨៥នាក់ ក្នុងខែឧសភា ឆ្នាំ២០១១ ជាកំណើន ៣៥%។ លទ្ធភាពដែលផ្ទុកអ្នកទោសបានរបស់ពន្ធនាគារនេះ ត្រូវបានប៉ាន់ស្មានថា មានរវាងពី៥២០កន្លែង ទៅ៧០០កន្លែង ហើយវាអាស្រ័យលើបទដ្ឋានដែលគេប្រើ។ ជាការពិតហើយ ដែលត្រូវតែធ្វើអ្វីមួយដើម្បីកាត់បន្ថយចំនួនអ្នកដែលនៅក្នុងពន្ធនាគារ។

[៣៩] "ស្បែកជាប់ខ្សែភ្លើង [Skin on the Cable]: ការចាប់ខ្លួនដោយខុសច្បាប់ ការឃុំខ្លួនដោយបំពាន និងការធ្វើទារុណកម្មលើអ្នកប្រើប្រាស់គ្រឿងញៀនក្នុងប្រទេសកម្ពុជា″ របាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១០ មាននៅគេហទំព័រ http://www.hrw.org/node/87692 ។

[៤០] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា១០។

ប៉ុន្តែគួរឲ្យសោកស្តាយណាស់ ដែលការប្តូរពីពន្ធនាគារទៅភ្នំបាក់នាពេលថ្មីៗ ធ្វើអោយមជ្ឈមណ្ឌលភ្នំបាក់មានការចង្អៀតណែនផងដែរ។ មជ្ឈមណ្ឌលភ្នំបាក់នេះគ្រោងឡើងសម្រាប់ផ្ទុកមនុស្សចំនួនតែ ១០០នាក់ ទេ ប៉ុន្តែឥឡូវនេះមានមនុស្សដល់ទៅ ១១៩នាក់ទៅហើយ។ មជ្ឈមណ្ឌលនេះ មានការខ្វះខាតទៅហើយនូវបុគ្គលិក ដើម្បីផ្តល់សេវាព្យាបាលសមស្របដល់អ្នកជាប់ឃុំឃាំង ហើយឥឡូវនេះស្ថានភាពបច្ចុប្បន្នកាន់តែពិបាកទៅៗ។ ស្ថានភាពហេដ្ឋារចនាសម្ព័ន្ធមជ្ឈមណ្ឌល គឺក្រោមកំរិតបទដ្ឋានដែលសមស្រប៖ បុរស និងស្ត្រីទទួលទានដំណេកក្នុងបន្ទប់ផ្សេងពីគ្នា ប៉ុន្តែរស់នៅច្របូកច្របល់គ្នានាពេលថ្ងៃ។ កុមារអាយុតិចជាងគេ ១៥ឆ្នាំ (ប្រហែលជាក្មេងជាងនេះទៅទៀត)[៤១] រស់នៅដោយសម្របខ្លួនជាមួយនឹងមនុស្សពេញវ័យ។

នៅខណៈពេលនេះដែរ ពន្ធនាគារខេត្តបន្ទាយមានជ័យនៅតែមានភាពចង្អៀតណែន ហើយមានអ្នកទោសថ្មីៗទៀត នៅតែបន្តហូរចូលពន្ធនាគារនេះ មូលហេតុមួយនៃបញ្ហានេះ ទំនងជាការបង្ក្រាបនាពេលថ្មីៗនេះលើបទល្មើសគ្រឿងញៀន ដែលចេញបញ្ជាដោយអគ្គស្នងការនគរបាលជាតិ ក្នុងខែមេសា ឆ្នាំ២០១១។ តាមការប៉ាន់ស្មានខ្លះថា មានមនុស្សជិត ៥០០នាក់ ត្រូវបានចាប់ខ្លួននៅទូទាំងប្រទេសក្នុងខែបន្ទាប់ពីមានបទបញ្ជានេះ[៤២]។ ប៉ុន្តែភាពពុះកញ្ជ្រោលនៃ ករណីគ្រឿងញៀន មានចាប់តាំងតែពីមុនពេលមានបទបញ្ជាមកម្ល៉េះ។ មន្ត្រីពន្ធនាគារខេត្តបន្ទាយមានជ័យបានទទួលស្គាល់ថា បានទទួលចូលនូវអ្នកទោសថ្មីប្រមាណជា២០០នាក់ ដែលជាអ្នកជាប់ចោទពីបទពាក់ព័ន្ធគ្រឿងញៀន ចាប់តាំងពីខែមករា ឆ្នាំ២០១១មក។

## *"ការផ្ទេរអ្នកទោសពីកន្លែងមួយទៅកន្លែងមួយ" មិនមែនជាដំណោះស្រាយចំពោះបញ្ហាភាពចង្អៀតណែនទេ*

ទោះបីជាគោលបំណងនៃការកាត់បន្ថយបញ្ហាចង្អៀតណែនរបស់អ្នកទោស នៅពន្ធនាគារ ខេត្តបន្ទាយមានជ័យ ជាការគួរកោតសរសើរ ប៉ុន្តែការផ្ទេរអ្នកទោសទៅកាន់មជ្ឈមណ្ឌលភ្នំបាក់បង្ហាញពីវិធីផ្សេងមួយនៃដំណោះស្រាយបែបដដែលៗចំពោះបទល្មើស ដែលប្រទេសកម្ពុជាបានប្រើប្រាស់ និងប្រើច្រើនហួសហេតុអស់រយៈពេលប្រមាណជា២០ឆ្នាំមកហើយ គឺការឃុំឃាំង។ នេះ គឺជាបំណងដើម្បីដោះស្រាយបញ្ហាចង្អៀតណែនតាមរយៈការ

[៤១] សូមមើលរូបភាពនៅទំព័រ ២៣

[៤២] វង់ សុខេង "នគរបាលព្រមានការបែកធ្លាយព័ត៌មានគ្រឿងញៀន" *កាសែតភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១១។

លាក់បំពួនអ្នកទោស។ ជាជាងការស្វែងរកកន្លែងថ្មីៗសម្រាប់ជនដែលសង្គម "មិនគួរឲ្យចង់ឃើញ" រាជរដ្ឋាភិបាលគួរតែស្វែងរកនូវដំណោះស្រាយថ្មីបែបទំនើបសមស្របជាងនេះ។

អ្នកប្រើប្រាស់គ្រឿងញៀនមិនសមស្របនឹងរស់នៅក្នុងពន្ធនាគារទេ[៤៣]។ ការដាក់ពន្ធនាគារអ្នកប្រើប្រាស់គ្រឿងញៀន គឺជាដំណោះស្រាយទៅរកការព្យាបាលប្រកបដោយការចំណាយខ្ពស់គ្មានប្រសិទ្ធិភាព និងមិនអាចមានដំណើរការបានត្រឹមត្រូវឡើយ។

បើសិនជារដ្ឋមានភាពប្រាកដប្រជាចំពោះការព្យាបាលសារធាតុញៀន ដែលជាជម្រើសផ្សេងពីការឃុំឃាំងក្នុងពន្ធនាគារ រាជរដ្ឋាភិបាលគួរតែពិចារណាលើកម្មវិធីព្យាបាលតាមសហគមន៍ ជាកម្មវិធីដែលអ្នកចូលរួមអោយគេព្យាបាលបានវិលត្រលប់ទៅផ្ទះវិញនៅពេលយប់។ យ៉ាងតិចណាស់មានកម្មវិធីបែបនេះចំនួន១០ ដែលកំពុងតែដំណើរការក្នុងខេត្តបន្ទាយមានជ័យនាពេលថ្មីៗនេះ រួមមានទាំងនៅមន្ទីរពេទ្យបង្អែកសិរីសោភ័ណ្ឌ មន្ទីរពេទ្យបង្អែកប៉ោយប៉ែត មណ្ឌលសុខភាពបន្ទាយនាង មណ្ឌលសុខភាពទឹកថ្លា មណ្ឌលសុខភាពអូរអំពិល មណ្ឌលសុខភាពកំពង់ស្វាយ មណ្ឌលសុខភាពព្រះពន្លា មណ្ឌលសុខភាពម៉ាឡៃ មណ្ឌលសុខភាពប៉ោយប៉ែត១ និងមណ្ឌលសុខភាពអូរបីជាន់។ ព្រះរាអាជ្ញាគួរតែពិនិត្យមើលរកការប្រើប្រាស់ជម្រើសមួយនៃជម្រើសព្យាបាលសារធាតុញៀន នៅឯមណ្ឌលសុខភាពទាំងអស់នេះ ជាជាងការមើលតែត្រឹមជម្រើសនៃការឃុំឃាំង។

ការឆ្ពោះទៅរកផ្លូវដោះស្រាយតាមសហគមន៍មានផលប្រយោជន៍ជាច្រើនៈ មិនចំណាយច្រើន ពីព្រោះមណ្ឌលមិនបាច់ផ្តល់កន្លែងស្នាក់នៅនិងចញ្ចឹមអ្នកចូលរួមទេ កម្មវិធីនេះលើកទឹកចិត្តអោយមានការទទួលខុសត្រូវជាបុគ្គល និងជួយឲ្យអ្នកចូលរួមរក្សា (ឬបង្កើត) ទំនាក់ទំនងជាមួយសហគមន៍របស់អ្នកទាំងអស់នោះ។ កម្មវិធីអាចនៅតែជាការតំរូវតាមរយៈដីកាពីតុលាការ និងដោយបញ្ចូលនូវការដាក់ទណ្ឌកម្មកាន់តែធ្ងន់ធ្ងរចំពោះជនទាំងឡាយណាដែលមិនចូលរួមក្នុងកម្មវិធីនេះ។ ប៉ុន្តែ ជាជម្រើសផ្សេង ពួកគេមិនគួរចាប់ផ្តើមជាមួយនឹងការបង្ខំឃុំឃាំងក្នុងពន្ធនាគារទេ នៅពេលខកខានមិនចូលរួមក្នុងកម្មវិធីនេះ[៤៤]។

---

[៤៣] តាមពិត "ការធ្វើសង្គ្រាមនឹងគ្រឿងញៀន" ដោយផ្តោតទាំងស្រុងតែទៅលើការដាក់អ្នកប្រើប្រាស់គ្រឿងញៀន ចូលក្នុងបទល្មើសព្រហ្មទណ្ឌ បានកំពុងតែមានការពិនិត្យយ៉ាងហ្មត់ចត់នាពេលថ្មីៗនេះ។ គណៈវិនិច្ឆ័យរបស់ពិភពលោក ដែលមានអតីតប្រមុខរដ្ឋនានា និងមន្ត្រីអង្គការសហប្រជាជាតិ បានហៅសកម្មភាពនេះ ក្នុងខែមិថុនា ឆ្នាំ២០១១ ថាជាការ "បរាជ័យ" ទាំងស្រុង។ "យោងតាមការប៉ាន់ប្រមាណរបស់អង្គការសហប្រជាជាតិ មានអ្នកប្រើប្រាស់គ្រឿងញៀនប្រមាណជា ២៥០លាននាក់ក្នុងពិភពលោក។ "យើងមិនអាចប្រព្រឹត្តិទៅលើពួកគេ ទាំងអស់នោះក្នុងនាមពួកគេជាឧក្រិដ្ឋជនបានទេ។" " ទុ ថាញ់ ហា , គណៈវិនិច្ឆ័យអន្តរជាតិ ប្រកាសថា "សង្គ្រាមប្រឆាំងនឹងគ្រឿងញៀន "បរាជ័យ", ឌឹហ្គ្លូប និង ម៉េល [The Globe and Mail] ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១១។ របាយការណ៍របស់ក្រុមនេះមាននៅគេហទំព័រ http://www.globalcommissionondrugs.org/Report

[៤៤] ចំណុចនេះមើលទៅគ្មានអនាគតភ្លឺថ្លាទេ ជាពិសេសជាមួយនឹងច្បាប់ថ្មីស្តីពីគ្រឿងញៀន ដែលរំពឹងនឹងត្រូវអនុម័តនាពេលណាមួយក្នុងឆ្នាំ២០១១។ ទោះបីជាពង្រាងច្បាប់កែប្រែចុងក្រោយបំផុតមិនទាន់ត្រូវបានចែកចាយជាសាធារណៈ ប៉ុន្តែពង្រាងដំបូងៗមាននូវវិធានការនានាដែលពិបាកយល់ និងខុសឆ្គង។ ក្នុងចំនោមកត្តាផ្សេងទៀត គឺពង្រាងដំបូងកំណត់ "អ្នកញៀនគ្រឿងញៀន" គឺជនណាដែល "ប្រើប្រាស់គ្រឿងញៀន និងស្ថិតក្រោមឥទ្ធិពលនៃគ្រឿងញៀន"

កម្មវិធីបែបនេះគួរតែរួមមានទាំងកម្មវិធីព្យាបាលដែលមាន ការទទួលស្គាល់ត្រឹមត្រូវតាមច្បាប់ និងផ្អែកតាមភស្តុតាងវិទ្យាសាស្ត្រ មិនមែនតាមបែបប្រពៃណី "បញ្ចេញញើសដើម្បីអោយសារធាតុញៀនចេញតាមញើស" ដែលកំពុងតែត្រូវបានប្រើប្រាស់នាពេលបច្ចុប្បន្ន។

**ទម្លាក់ទម្ងន់លើ: បទល្មើសតូចតាច តែមានថិរវេលាយូរ**

ផ្នែកដែលជាកង្វល់ចុងក្រោយសម្រាប់ឆ្នាំ២០១០ គឺអាជ្ញាធរនៅតែចង់អនុវត្តក្នុងការដាក់ទោសធ្ងន់ធ្ងរទៅលើបទល្មើសមជ្ឈឹម (ការឃុំឃាំងជាបណ្តោះអាសន្នរង់ចាំសវនាការ)។ ប្រព័ន្ធនេះហាក់ដូចជាមិនមានលទ្ធភាពបង្វែរករណីតូចតាចចេញពីប្រព័ន្ធតុលាការ ហើយកត្តានេះ គឺជាបញ្ហាមានជាយូរអង្វែងមកហើយ។ ប៉ុន្តែកាន់តែមានបញ្ហាច្រើនឡើងៗ ដោយសារតែអ្នកទោសនៅតាមពន្ធនាគារមានចំនួនច្រើនលើសលុប។

បញ្ហាមិនមែនមានកំរិតត្រឹមតែចំពោះអ្នកទោសដែលមានថិរវេលាយូរនោះទេ មានបញ្ហាដទៃទៀត ដែលនាំអោយមានភាពចង្អៀតណែនអ្នកទោសនៅតាមពន្ធនាគារ គឺអាចជាចំនួនច្រើនលើសលុបនៃអ្នកទោស ដែលមានថិរវេលាខ្លីចំពោះបទល្មើសដែលមិនចាំបាច់នឹងទទួលទោសជាប់ពន្ធនាគារទាល់តែសោះ។ ជាឧទាហរណ៍ ទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធនាគារនាពេលថ្មីៗបង្ហាញថា ប្រព័ន្ធពន្ធនាគារបានបន្តទទួលយកអ្នកទោសថ្មីចំនួន ៦,៨៣៦នាក់ ក្នុងអំឡុងឆ្នាំ២០១០[៤៥]។ នេះគឺជា ចំនួនដ៏គួរឲ្យកត់សំគាល់ និងចាត់ទុកជាចំនួនអ្នកទោសសរុបក្នុងខែធ្នូ ឆ្នាំ២០១០ ត្រូវនឹង១៤,០៤៣ នាក់។

ស្ថិតិនេះហាក់ដូចជាធ្វើអោយអស់សង្ឃឹម បើយើងក្រលេកមើលទៅក្រោយវិញ ប៉ុន្តែនេះគឺជាការសង្ឃឹមសំរាប់លទ្ធភាពដែលអាចធ្វើបាននាពេលអនាគត: មានន័យថា កិច្ចខិតខំរួមគ្នាដោយថៅក្រម និងព្រះរាជអាជ្ញា អាចមិនត្រឹមតែបញ្ឈប់កំណើនអ្នកទោសតាមពន្ធនាគារប៉ុណ្ណោះទេ ប៉ុន្តែវាពិតជាអាចកាត់បន្ថយដល់ចំនួនអ្នកទោសសរុបនៅក្នុងពន្ធនាគារ។ ឧទាហរណ៍ បើសិនជាការទទួលយកអ្នកទោសចូលក្នុងពន្ធនាគារ ត្រូវបានកាត់បន្ថយចំនួនពាក់កណ្តាលសម្រាប់ឆ្នាំ២០១០ នោះចំនួនអ្នកទោសសរុបនឹងថយចុះ។

នេះគឺជាឧទាហរណ៍មួយចំនួននៃការដាក់ទោសដែលមិនមានភាពសមាមាត្រ ទៅនឹង "កំហុស" ដែលត្រូវបានចោទ ដែលអង្គការលីកាដូបានសរសេរចងក្រងនាឆ្នាំថ្មីៗនេះ៖

---

និងអនុញ្ញាតិអោយមានការបង្ខំអ្នកប្រើប្រាស់គ្រឿងញៀនអោយទទួលការព្យាបាល ដោយមិនស្ម័គ្រចិត្តរហូតដល់រយ:ពេល២ឆ្នាំ។ *សូមអាន* ឆាយ ចាន់ឌីណា និង ចេមស៍ អូទូល "ច្បាប់ស្តីពី គ្រឿងញៀន ក្នុងដំណាក់កាលចុងក្រោយ" កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១១។

[៤៥] តួលេខចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០។ *សូមអាន* "របាយការណ៍ស្តីពីការងារសំរេចបានក្នុងឆ្នាំ២០១១ និងផែនការសម្រាប់ឆ្នាំ២០១១" របស់អគ្គនាយកដ្ឋានពន្ធនាគារ ផ្សព្វផ្សាយក្នុងខែមករា ឆ្នាំ២០១១

- ខេត្តព្រះសីហនុ: នៅដើមឆ្នាំ២០១០ អនីតិជនត្រូវបានកាត់ទោសអោយជាប់ពន្ធនាគាររយ:ពេល ៦ខែ ចំពោះការទំលុះទំលាយបង្ហូច។
- ខេត្តបន្ទាយមានជ័យ: អនីតិជនដែលជាអ្នករើសអេតចាយ ត្រូវបានចោទប្រកាន់ពីបទប្លន់ ចំពោះការរើសយកសំបកកង់ឡានដែលគេប្រើរួច ដែលគេទុកចោលនៅខាងក្រៅផ្ទះ។ អនីតិជនបានសន្មត់ថាជារបស់ដែលគេបោះចោល។ អនីតិជននោះបានស្ថិតក្នុងការឃុំខ្លួនជាបណ្តោះអាសន្នរងចាំសវនាការតាំងតែពីខែធ្នូ ឆ្នាំ២០១០។
- ខេត្តបន្ទាយមានជ័យ: បុគ្គលបីរូបត្រូវបានចាប់ខ្លួននៅដើមខែឧសភា ឆ្នាំ២០១១ និងត្រូវបានចោទប្រកាន់ពីបទប្លន់ ចំពោះការលួចបេះផ្លែ និងគ្រាប់ស្វាយចន្ទីចំនួន ១គីឡូក្រាមពីក្នុងចំការមួយ ហើយដែលបុគ្គលទាំងបីនាក់នេះកំពុងតែជាប់ឃុំឃាំងបណ្តោះអាសន្នរង់ចាំសវនាការ។
- ខេត្តស្វាយរៀង: បុរសម្នាក់ដែលអះអាងថា ខ្លួនបានទទួលទានដំណេកនៅក្នុងក្រោលគោរបស់គេត្រូវបានចោទប្រកាន់ដោយម្ចាស់គោនោះថាបានប៉ុនប៉ងធ្វើសកម្មភាពលួច។ បុរសនោះត្រូវបានចាប់ខ្លួនក្នុងខែមករា ឆ្នាំ២០១១ ហើយក្រោយមកត្រូវបានកាត់ទោសអោយជាប់ពន្ធនាគាររយ:ពេល ១៨ខែ។
- ខេត្តស្វាយរៀង: យុវជនអាយុ១៨ឆ្នាំ ម្នាក់ត្រូវបានចាប់ខ្លួនក្នុងខែធ្នូ ឆ្នាំ២០១០ ហើយត្រូវបានចោទប្រកាន់ពីបទលួចមាន់មួយ។ យុវជននោះត្រូវបានកាត់ទោសអោយជាប់ពន្ធនាគាររយ:ពេល ១ឆ្នាំ។
- ខេត្តកំពង់ចាម: បុរសម្នាក់ត្រូវបានចាប់ខ្លួនក្នុងខែតុលា ឆ្នាំ២០១០ និងត្រូវបានចោទប្រកាន់ពីបទលួចប្រេងឆាមួយដប។ ក្រោយមក បុរសនោះត្រូវបានទទួលការកាត់ទោស និងផ្តន្ទាទោសអោយជាប់ពន្ធនាគាររយ:ពេល៧ខែ ពីបទចោរកម្ម។
- ខេត្តកំពង់ចាម: បុរសម្នាក់ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទលួចដែករបារ ហើយបុរសនោះត្រូវបានគេដាក់ឃុំឃាំងជាបណ្តោះអាសន្នរងចាំសវនាការ តាំងពីខែកុម្ភ: ឆ្នាំ២០១១។
- ខេត្តកំពង់ចាម: បុរសម្នាក់ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទលួចជ័រកៅស៊ូស្រស់ទម្ងន់ប្រហែលជា១គីឡូក្រាម។ បុរសនោះត្រូវបានគេដាក់ឃុំឃាំងជាបណ្តោះអាសន្នរងចាំសវនាការតាំងពីខែធ្នូ ឆ្នាំ២០១០។

អង្គការលីកាដូ ក៏បានចងក្រងផងដែរនូវករណីនៃការដាក់ទោសហួសហេតុមួយចំនួនចំពោះអ្នកដែលមិនបានប្រព្រឹត្តបទល្មើសទាល់តែសោះ មានដូចជា អ្នកការពារសិទ្ធិមនុស្ស

ជនរងគ្រោះពីការរំលោភយកដីធ្លី សកម្មជន និងអ្នកដទៃទៀតដែលពាក់ព័ន្ធក្នុងសកម្មភាពនយោបាយ។ ករណីទាំងអស់នោះ ត្រូវបានសរសេរចងក្រងឡើងយ៉ាងពិស្តារក្នុងរបាយការណ៍ថ្មីៗរបស់អង្គការលីកាដូ ស្តីពីអ្នកការពារសិទ្ធិមនុស្ស[៤៦] និងសេរីភាពខាងការបញ្ចេញមតិ[៤៧]។

គោលបំណងនៃការលើកយកករណីទាំងអស់នេះមកបង្ហាញ គឺមិនមែនមានន័យថាជនរងគ្រោះមិនត្រូវបានគេយកចិត្តទុកដាក់នោះទេ ផ្ទុយទៅវិញ គឺសម្រាប់ជាការរំលឹកប្រាប់ថា ពន្ធនាគារ និងការឃុំឃាំងជាបណ្តោះអាសន្ន ត្រូវបានប្រើប្រាស់សម្រាប់ដាក់ទណ្ឌកម្មជាចាំបាច់លើរាល់ការប្រព្រឹត្តិបទល្មើសទាំងអស់នៅក្នុងប្រទេសកម្ពុជា។ ទិន្នន័យក្នុងរបាយ-ការណ៍នេះបង្ហាញយ៉ាងច្បាស់ថា ចំណាត់ការបែបនេះមិនមាននិរន្តរភាពទេ។ ទំហំសម្រាប់ផ្តល់អោយអ្នកទោសក្នុងពន្ធនាគារ គឺជាកន្លែងមួយដែលមានតិចតួចបំផុត ហើយកំពុងតែមានការខ្វះខាតទៅៗ។ ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ គួរតែពិចារណាលើបញ្ហាដែលកំពុងតែមានជាក់ស្តែងនេះ។ ជាការពិតណាស់ ពន្ធនាគារមិនមែនគ្រាន់តែជាមធ្យោបាយមួយគត់ដើម្បីដោះស្រាយករណីនៃការលួចមាន់មួយមានតម្លៃ ៥ដុល្លាសហរដ្ឋអាមេរិក នោះទេ។

---

[៤៦] "ការវាយប្រហារ និងការគំរាមកំហែង ឮលើអ្នកការពារសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៨ – ២០០៩" របាយការណ៍អង្គការលីកាដូ បានចេញផ្សព្វផ្សាយក្នុងខែកញ្ញា ឆ្នាំ២០១០ មាននៅគេហទំព័រ http://www.licadho-cambodia.org/reports.php?perm=143

[៤៧] "សេរីភាពនៃការបញ្ចេញមតិនៅក្នុងប្រទេសកម្ពុជា: លិទ្ធិប្រជាធិបតេយ្យក្លែងក្លាយ" របាយការណ៍អង្គការ លីកាដូ បានចេញផ្សព្វផ្សាយក្នុងខែធ្នូ ឆ្នាំ២០១០ មាននៅគេហទំព័រ http://www.licadho-cambodia.org/reports.php?perm=149

# ៣- អនុសាសន៍ និងការពិនិត្យឡើងវិញ

របាយការណ៍លើកមុនរបស់អង្គការលីកាដូ ស្តីពីភាពចង្អៀតណែនរបស់អ្នកទោស បានផ្តល់នូវអនុសាសន៍ដើម្បីកាត់បន្ថយបញ្ហាចង្អៀតណែនក្នុងពន្ធនាគារ។ អង្គការលីកាដូ សូមបន្តនូវអនុសាសន៍សំខាន់ៗចំនួនប្រាំ។ តើរដ្ឋាភិបាលបានអនុវត្តអ្វីខ្លះចំពោះអនុសាសន៍ ដែលអង្គការ លីកាដូបានចងក្រង និងផ្ញើជូនកាលពីឆ្នាំមុន?

**►► សូមរដ្ឋាភិបាលលោកមានវិធានការវាយតម្លៃពីគោលនយោបាយយុត្តិធម៌ព្រហ្មទណ្ឌ ដោយចេញពីទស្សនៈវិស័យជាប្រព័ន្ធច្រើនថែមទៀត ដើម្បីកុំអោយក្រសួងមហាផ្ទៃ និង អគ្គនាយកដ្ឋានពន្ធនាគារ ដោះស្រាយបញ្ហាទាំងនេះដោយម្នាក់ឯង (ដូចជាបញ្ហាចំនួនច្រើន លើសលុបនៃអ្នកទោសនៅតាមពន្ធនាគារជាដើម)។ នៅក្នុងការផ្តួចផ្តើមគំនិតនេះ សូមមេត្តា ឲ្យរាជរដ្ឋាភិបាលលោករៀបចំចងក្រងឡើងនូវព័ត៌មានត្រឹមត្រូវ និងអាចជឿទុកចិត្តបានអំពី ចំនួនអ្នកទោសទាំងអស់ដែលឃុំឃាំងនៅតាមពន្ធនាគារ ដែលរួមមានទាំងសេចក្តីពិស្តារអំពី ថិរវេលានៃទណ្ឌកម្មជាប់ពន្ធនាគារ បទល្មើសដែលបានប្រព្រឹត្ត និងអាយុរបស់ជនប្រព្រឹត្ត ល្មើសទាំងអស់នេះ ដើម្បីជួយដល់ការធ្វើសេចក្តីសំរេចចិត្តនានាចំពោះគោលនយោបាយ យុត្តិធម៌ព្រហ្មទណ្ឌ។**

មន្ត្រីរដ្ឋាភិបាលមួយចំនួនបានទទួលស្គាល់ពីបញ្ហាចង្អៀតណែនរបស់អ្នកទោសតាម ពន្ធនាគារ និងអំពីតម្រូវការចំពោះការដោះស្រាយបញ្ហានេះ។ អគ្គនាយកដ្ឋានពន្ធនាគារក៏ បានកំណត់ថា នេះជាកត្តាចម្បងក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីធ្វើអោយប្រសើរឡើងដល់ ប្រព័ន្ធពន្ធនាគារ។ ទាំងអស់នេះ គឺជាជំហានដ៏វិជ្ជមាន។ ក៏ប៉ុន្តែជាការសោកស្តាយ ដោយ សារអគ្គនាយកដ្ឋានពន្ធនាគារមិនបានគ្រប់គ្រងលើចំនួនអ្នកទោស ដែលបានទទួលទេ ហើយអ្នកដើរតួសំខាន់ក្នុងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ដែលមានក្រសួងយុត្តិធម៌ ព្រះរាជ-អាជ្ញា និងតុលាការ ក៏មិនទាន់បានអនុវត្តការកែទម្រង់អោយបានប្រាកដប្រជានោះដែរ។

ប៉ុន្តែអគ្គនាយកដ្ឋានពន្ធនាគារក៏មានចំនុចខ្សោយមួយដែរគឺៈ ពន្ធនាគារហាក់បីដូចជា មានជំហានថយក្រោយលើទិន្នន័យត្រឹមត្រូវ។ ទិន្នន័យត្រឹមត្រូវ គឺជាកត្តាសំខាន់សម្រាប់ ការវាយតម្លៃលើមូលហេតុ និងវិសាលភាពនៃបញ្ហាចង្អៀតណែនរបស់អ្នកទោស។

មន្ត្រីពន្ធនាគារបានប្រាប់អ្នកស្រាវជ្រាវអង្គការលីកាដូថា មានការយល់ច្រឡំក្នុងការ ចាត់អ្នកទោសចូលជាប្រភេទអ្នកជាប់ឃុំឃាំងបណ្តោះអាសន្នរង់ចាំសវនាការ (ពិរុទ្ធជន) ឬ

ជាអ្នកដែលបានកាត់ទោសរួចហើយ(ទណ្ឌិត)។ ជាលទ្ធផល អង្គការលីកាដូហាក់ដូចជាទទួលបាននូវទិន្នន័យមិនត្រឹមត្រូវពីពន្ធនាគារខ្លះៗ។ ឧទាហរណ៍ ទិន្នន័យរបស់អង្គការលីកាដូបង្ហាញថា មានអ្នកទោសជាប់ឃុំឃាំងជាបណ្តោះអាសន្នរង់ចាំសវនាការចំនួន ៣,៣៩៩នាក់ ក្នុងខែធ្នូ ឆ្នាំ២០១០ នៅពន្ធនាគារទាំង១៨ ដែលឃ្លាំមើលដោយអង្គការលីកាដូ។ ប៉ុន្តែទិន្នន័យផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធនាគារសម្រាប់ខែដូចគ្នា បង្ហាញថាមានអ្នកទោសជាប់ឃុំឃាំងជាបណ្តោះអាសន្នរង់ចាំសវនាការចំនួន៤,៨៣០នាក់ ដែលជាទិន្នន័យមានភាពខុសគ្នាចំនួន១,៤៨៦នាក់ ខុសគ្នាជាមួយនឹងទិន្នន័យរបស់អង្គការលីកាដូ (៣,៣៩៩នាក់)។ ថ្វីត្បិតតែទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធនាគាររាប់បញ្ចូលពន្ធនាគារចំនួនទាំង៧ ដែលជាពន្ធនាគារមិនស្ថិតក្រោមការឃ្លាំមើលរបស់អង្គការលីកាដូ ហើយដែលពន្ធនាគារទាំងនោះ មានចំនួនអ្នកទោសសរុបចំនួនត្រឹមតែ១,៤៩៦នាក់។ ចំនួននេះពិតជាមិនបានរាប់បញ្ចូលអ្នកជាប់ឃុំឃាំងជាបណ្តោះអាសន្នរង់ចាំសវនាការចំនួន ១,៤៨៦នាក់នោះទេ ដែលស្តែងអោយឃើញពីភាពយល់ច្រឡំលើការកំណត់ស្ថានភាពឃុំឃាំងនៃអ្នកទោសមួយចំនួន។

*អង្គការលីកាដូសូមផ្តល់អនុសាសន៍ជាថ្មីម្តងទៀតចេញពីអនុសាសន៍ឆ្នាំ២០១០ កន្លងមក ហើយសូមសំណូមពរដល់អគ្គនាយកដ្ឋានពន្ធនាគារសូមលោកធ្វើយ៉ាងណាអោយមានការយល់ដឹងដូចៗគ្នា នៅគ្រប់ពន្ធនាគារទាំងអស់ អំពីប្រភេទនៃអ្នកជាប់ឃុំឃាំងជាបណ្តោះអាសន្នរង់ចាំសវនាការ ដើម្បីធានាអោយទិន្នន័យនៃចំនួនអ្នកទោសមានភាពស្របគ្នា និងមានភាពសុក្រឹត្យឡើង។*

*ជាបន្ថែមទៀត អង្គការលីកាដូ សូមសំណូមពរដោយទទូចដល់ អគ្គនាយកដ្ឋានពន្ធនាគារ សូមលោកមេត្តាដឹកនាំការសិក្សាជា បន្ទាន់មួយលើពន្ធនាគារទាំងអស់នៅទូទាំងប្រទេសដែលអាចធ្វើទៅបានជាមួយនឹងជំនួយពីដៃគូរអន្តរជាតិ ដើម្បីគណនាឲ្យពិតប្រាកដអំពីលទ្ធភាពដែលផ្ទុកអ្នកទោសបាន។ យើងខ្ញុំជឿជាក់ថា ការសិក្សានេះនឹងនាំអោយមានការកំណត់បានច្បាស់ជាបន្តទៀតពីភាពធ្ងន់ធ្ងរនៃវិបត្តិចង្អៀតណែនខ្លាំង និងពីភាពបន្ទាន់នៃបញ្ហា ដែលនឹងត្រូវរិះរកដំណោះស្រាយបែបណា។*

►►សូមក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ និងដៃគូរពាក់ព័ន្ធ លោកគួរតែចាត់នូវវិធានការនានាដើម្បីបង្កើតឡើងនូវហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា ដើម្បីអនុវត្តន៍ក្នុងកម្រិតធំទូលាយមួយនៃការដាក់ទណ្ឌកម្មដោយមិនប្រើតែវិធីឃុំឃាំងក្នុងពន្ធនាគារ។ យន្តការទាំងអស់នេះ

គួររួមបញ្ចូលទាំងការហ្វឹកហ្វឺន អំពីការប្រើប្រាស់ដ៏ត្រឹមត្រូវនៃការដាក់ទណ្ឌកម្មដោយមិនប្រើការឃុំឃាំងក្នុងពន្ធនាគារដល់ចៅក្រម ព្រះរាជអាជ្ញា បុគ្គលិក និងមេធាវីការពារក្តី។ យន្តការនេះក៏ត្រូវមានការបង្កើតនាយកដ្ឋានសាកល្បង ឬការិយាល័យរដ្ឋាភិបាលស្រដៀងគ្នានេះ ដើម្បីផ្តោតជាសំខាន់លើការគ្រប់គ្រង និងស្តារនីតិសម្បទាជនល្មើសដែលទទួលបានការដាក់ទណ្ឌកម្មមិនជាប់ឃុំឃាំងក្នុងពន្ធនាគារ។

អង្គការលីកាដូមិនបានឃើញការរីកចម្រើនគួរអោយកត់សម្គាល់លើអនុសាសន៍នេះទេ។ ការប្រើប្រាស់ជម្រើសផ្សេងក្រៅ ពីការដាក់ពន្ធនាគារនៅតែមានភាពកម្រ។

***អាស្រ័យហេតុនេះ ជាថ្មីម្តងទៀត អង្គការលីកាដូសូមផ្តល់អនុសាសន៍ដែលបានផ្តល់កាលពីឆ្នាំ២០១០។***

►►សូមក្រសួងយុត្តិធម៌ លោកមេត្តាចាត់វិធានការជាបន្ទាន់ ដើម្បីអនុវត្តសវនាការផ្តន្ទាទោសមិនឃុំឃាំងក្នុងពន្ធនាគារ ចំពោះប្រភេទជនល្មើសមួយចំនួន។ សវនាការនេះគួរចាប់ផ្តើមឡើង ដោយក្រុមការងារពិសេសពិនិត្យមើលឡើងវិញ លើករណីដែលអ្នកទោសទាំងអស់ដែលបានវិនិច្ឆ័យទោសអោយជាប់ពន្ធនាគាររយៈពេល៣ឆ្នាំ ឬតិចជាងនេះ ដែលនេះអាចជាចំណុចចាប់ផ្តើមនៃសេវាសហគមន៍។

អង្គការលីកាដូ មិនបានឃើញការរីកចម្រើនគួរអោយកត់សម្គាល់លើអនុសាសន៍នេះទេ។ *ដូច្នេះជាថ្មីម្តងទៀត អង្គការលីកាដូសូមផ្តល់អនុសាសន៍ដែលបានផ្តល់កាលពីឆ្នាំ២០១០។*

**►►សូមក្រសួងយុត្តិធម៌ និងតុលាការ លោកមេត្តាគួរតែចាប់ផ្តើមជាបន្ទាន់នូវការបង្កើនការប្រាស់វិធានការមិនដាក់ពន្ធនាគារក្នុងរយៈពេលមុនសវនាការដល់អ្នកជាប់ឃុំឃាំងបណ្តោះអាសន្នរងចាំសវនាការចំនួនប្រហែលជា ៣,៨០០នាក់។ បច្ចុប្បន្នចំនួននេះបានដាក់បន្ទុកដល់ប្រព័ន្ធពន្ធនាគារប្រទេសកម្ពុជា។ [សេរីភាពនៅក្រៅឃុំមុនពេលសវនាការ] គួរតែជាច្បាប់ដែលត្រូវតែអនុវត្តមិនមែនជាការលើកលែងទេ ចំពោះបទល្មើសតូចតាច និងបទល្មើសមិនហិង្សា [ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា២០៣]។**

មានការសង្កេតឃើញថាមានដំណើរថយក្រោយលើអនុសាសន៍នេះ។ ការប្រៀបធៀប អោយបានត្រឹមត្រូវមានការពិបាក ដោយសារតែមានភាពមិនប្រក្រតីដែលអគ្គនាយកដ្ឋានពន្ធនាគារ ចេញផ្សាយតួលេខថ្នាក់ជាតិ និងបញ្ហានៃការយល់ច្រលំចំពោះការកំណត់អំពី

ប្រភេទនៃអ្នកជាប់ឃុំឃាំង ដូចដែលបានកត់សម្គាល់ពីខាងដើមនៃរបាយការណ៍នេះ។ ទោះបីជាយ៉ាងណាក៏ដោយ គិតមកត្រឹមខែមេសា ឆ្នាំ២០១១ អគ្គនាយកដ្ឋានពន្ធនាគារបានរាយការណ៍ថា មានអ្នកជាប់ឃុំឃាំងបណ្តោះអាសន្នរងចាំសវនាការនៅទូទាំងប្រទេសចំនួន ៥,៣៩៤នាក់។ នេះ មានន័យថា អ្នកជាប់ឃុំឃាំងបណ្តោះអាសន្នរងចាំសវនាការមាន ៣៦% នៃចំនួនអ្នកជាប់ឃុំឃាំងសរុបទាំងអស់។ ចំនួននេះប្រៀបធៀបនឹងចំនួន ៣២% ក្នុងខែមិថុនា ឆ្នាំ២០១០។

(សម្គាល់: តួលេខ ៣,៨០០នាក់ ដែលបានសរសេរដកស្រង់ក្នុងអនុសាសន៍ដំបូង គឺសំដៅលើចំនួនអ្នកជាប់ឃុំឃាំងបណ្តោះអាសន្នរងចាំសវនាការ គិតមកត្រឹមខែមិថុនា ឆ្នាំ ២០១០ នៅពន្ធនាគារ១៨ ដែលឃ្លាំមើលដោយអង្គការលីកាដូ ហើយវាមិនមែនជាតួលេខនៃចំនួនអ្នកទោសសរុបថ្នាក់ជាតិទេ)។

រដ្ឋមានបំណងមួយ ដើម្បីកាត់បន្ថយចំនួនអ្នកទោសជាប់ឃុំឃាំងជាបណ្តោះអាសន្នរងចាំសវនាការ អាចគ្រាន់តែត្រូវបានមើលឃើញថាមិនបានជោគជ័យទេ។ ការបញ្ជូនអ្នកជាប់ឃុំឃាំងបណ្តោះអាសន្នរងចាំសវនាការ ទៅដាក់នៅមជ្ឈមណ្ឌលព្យាបាលសារធាតុញៀន គឺជាដំណោះស្រាយទាល់ច្រកមួយ: នេះគឺជាការបំពេញអោយការបង្កើតប្រព័ន្ធពន្ធនាគារដូចគ្នាមួយ។

*ជាថ្មីម្តងទៀត អង្គការលីកាដូ សូមផ្តល់អនុសាសន៍ដែលបានផ្តល់កាលពីឆ្នាំ២០១០ កន្លងទៅនេះ។*

*បើសិនជា រដ្ឋនៅតែបន្តប្រើប្រាស់មធ្យោបាយព្យាបាលសារធាតុញៀន ជាជម្រើសផ្សេងក្រៅពីការឃុំឃាំងជាបណ្តោះអាសន្ន រងចាំសវនាការ យើងខ្ញុំសូមអនុញ្ញាតផ្តល់អនុសាសន៍ ជូនថា ការព្យាបាលបែបនេះត្រូវតែ (១) ស្ម័គ្រចិត្ត (២) ព្យាបាលតាមសហគមន៍ និង(៣) ដោយផ្អែកលើវិធីសាស្ត្រ ព្យាបាលដែលមានភស្តុតាងតាមបែបវេជ្ជសាស្ត្រត្រឹមត្រូវ។ ជាសក្តានុពល អ្នកជាប់ឃុំឃាំងបណ្តោះអាសន្នរងចាំសវនាការរាប់រយនាក់អាចត្រូវបានដោះលែងអោយទៅចូលរួមក្នុងកម្មវិធីទាំងនេះ ដែលនឹងអាចជួយសម្រាលយ៉ាងសំខាន់ដល់បញ្ហាចង្អៀតណែននៅតាមពន្ធនាគារ។ សូមចៅក្រម និងព្រះរាជអាជ្ញា មេត្តាពិចារណាផងដែរ ដល់ការរៀបចំអោយមានឡើងនូវជម្រើសនៃការព្យាបាលអោយទៅជាកម្មវិធីបង្វែរមួយ ដូចជាយល់ព្រមលើកលែងបទចោទប្រកាន់ព្រហ្មទណ្ឌ ជាថ្នូរនឹងការបំពេញបានជោគជ័យក្នុងកម្មវិធីព្យាបាលសារធាតុញៀនតាមសហគមន៍ជាដើម។*

**►►ការឃុំឃាំងក្នុងពន្ធនាគារគួរតែត្រូវបានមើលឃើញថាជា ទណ្ឌកម្មដែលជាជម្រើសចុងក្រោយ ហើយមិនមែនជាជម្រើសដែលគ្មានជម្រើសអ្វីផ្សេងសម្រាប់លើគ្រប់បទល្មើស ទាំងអស់នោះទេ។**

អង្គការលីកាដូមិនបានឃើញការរីកចម្រើនគួរអោយកត់សម្គាល់លើអនុសាសន៍នេះទេ។ ដូច្នេះ*ជាថ្មីម្តងទៀត អង្គការលីកាដូ សូមផ្តល់អនុសាសន៍ដែលបានផ្តល់កាលពីឆ្នាំ ២០១០ និងសូមមេត្តាជម្រុញអោយមានការវិវឌ្ឍន៍រីកចម្រើនលើផ្នែកពីរដាក់លាក់គឺ:*

ក. ***កាត់បន្ថយការដាក់ទណ្ឌកម្មធ្ងន់ធ្ងរអោយជាប់ពន្ធនាគារ ចំពោះបទល្មើសតូចតាចដែលមិនពាក់ព័ន្ធនឹងអំពើហិង្សាលើអ្នកដទៃ និង***

ខ. ***លប់បំបាត់ការអនុវត្តនៃការបន្ថែមរយៈពេលជាប់ឃុំឃាំងក្នុងពន្ធនាគារ ចំពោះទណ្ឌកម្មទាក់ទងនឹងការមិនបង់ប្រាក់ពិន័យ ឬក៏ដាក់ទណ្ឌកម្មរបៀបនេះទន្ទឹមគ្នានឹងរយៈពេលនៃទោសជាប់ពន្ធនាគារពីដំបូង។***

□□□

http://www.licadho-cambodia.org